
សៀវភៅគតិលោក
ភាគទី៣



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

CHANBOKEO.COM
ឆែន បន្ទុះអាន

រឿងសត្វកន្លង់និងតឹង្គក់អួតឫទ្ធិគ្នា

មួយទៀតអ្នកមានបញ្ញាវៃ តតបសេចក្តីយកឈ្នះវិញ្ញក៍មានដូចនិទាន សត្វកន្លង់តតបនឹងពាក្យតឹង្គក់នោះឯង។

មានសត្វកន្លង់១ ហើរក្រៃបកេសរង្គានាកណ្តាលផ្លូវ បានយល់តឹង្គក់១លោតទៅខាងគុម្ពផ្កា ទើបសួរថា "បងតឹង្គក់ បងឯងទៅឯណា?"។ តឹង្គក់ជាសត្វអួតឫទ្ធិ តិតថា អញនឹងប្រាប់គតិនេះឲ្យកន្លង់កោតខ្លាចអញ តិតហើយទើបប្រាប់ថា "យើងទៅកាន់មហាស្រះឯព្រៃហេមពាន្ត ដើម្បីនឹងទៅចង់ស្រី, អើកន្លង់ឯងកោតយើងឬទេហះ?"។

ឯកន្លង់តបថា "បងឯងអាចទៅដល់ឬ? ព្រៃហេមពាន្តនោះឆ្ងាយម្ល៉ះ"។ "ឱ! យើងទៅវិលល្ងាចផងណ៎ាកន្លង់ ឯងសង្ស័យអ្វីឫទ្ធិយើងនេះ, អើខ្លួនចៅឯង តែធ្វើអ្វីនៅនេះ សូរឮដឹងៗនោះ?"។

កន្លង់បានឱកាសក៏តបថា "យើងហើរប្រទក្សិណភ្នំព្រះសុមេរុណ៎ាបងតឹង្គក់"។ "ឱ! ឯងហើរប្រទក្សិណជុំភ្នំព្រះសុមេរុនោះធំម្ល៉ះបានឬ?"។ "អើយើងហើរប្រទក្សិណក្នុង១ ថ្ងៃបាន៧ជុំផងណ៎ាបងតឹង្គក់, បងឯងខ្លាចឫទ្ធិយើងឬទេ?"។

ឯតឹង្គក់នោះក៏តបកាត់ទៀងថា "ខ្មោចអាឯងស្លាប១សុញ្ញទេ នៅអួតភរថាហើរប្រទក្សិណភ្នំព្រះសុមេរុ១ថ្ងៃ៧ជុំបាន អាណាទៅជឿឯងបាន"។

ឯកន្លង់ក៏តបថា "ខ្មោចអាឯងជើងខ្លី១សុញ្ញទេក៏អួតភរថាឯងទៅដល់ព្រៃហេមពាន្ត ទិល្ងាចវិញបាន អាណាទៅជឿឯងបាន"។ តឹង្គក់ក៏ទាល់ឈប់នៅ អស់សេចក្តីតែប៉ុណ្ណេះ។

រឿងធនញ្ជ័យបណ្ឌិតនឹងអ្នកប្រាជ្ញកោះលង្កា

មានអ្នកប្រាជ្ញមួយទៀតបញ្ញាយ៉ាងល្អិត និមិត្តតែឃើញអាការខាងក្រៅចេញមក ក៏អាចដឹងអាថ៌បញ្ចូលមនុស្សនោះបានដូចនិទានចៅធនញ្ជ័យបណ្ឌិត កាលអ្នកប្រាជ្ញកោះលង្កាទ្វីប តែចូលមកក្នុងព្រះនគរចោទរកអ្នកប្រាជ្ញនោះ សេចក្តីថា កាលណោះព្រះចៅក្រុងកោះលង្កា មានព្រះរាជាសារដល់មកព្រះចៅក្រុងស្រីអយុធ្យាថា ឲ្យទើសរកអ្នកប្រាជ្ញ អាចមានបញ្ញាដឹងលោកិយលោកាប្រៃបាលីភាសាឬឆ្លើយអាថ៌ បញ្ចូលក្នុងក្រៅបាន នឹងតតាំងនឹងអ្នកប្រាជ្ញកោះលង្កា។ ឯព្រះចៅក្រុងស្រីអយុធ្យា ក៏ដាក់ភ្នាក់ងារនោះ ឲ្យធនញ្ជ័យទទួលចោទឆ្លើយ តនឹងអ្នកប្រាជ្ញក្រុងលង្កាទើបចៅធញ្ជ័យទទួលភ្នាក់ងារចេញមក

ចាត់ចែង ឲ្យចៅភ្នាក់ងារកាត់ក្តានតូចធំ យកសំពត់ទុំបន្តិជាគម្នួន បានច្រើន ហើយឲ្យដាក់ក្នុងទូ ចាំកចំណងដើងប្រាប់ឈ្មោះទម្ងន់ នោះប្តែកៗទីទៃៗ។

ឯអ្នកប្រាជ្ញកោះលង្កា មកដល់បានចូលទៅមើល ក្នុងមន្ទីរហោត្រៃហ្លួង បានឃើញគម្នួនចៅធនញ្ជ័យច្រើនដូច្នោះ ក៏នឹកខ្លាចនឹកអរអាចិត្តគិតថា ស្រុកគេនេះមានគម្នួនច្រើនណាស់ ឯងនឹងលេងខាងដើងគម្នួននោះយល់ជាមិនឈ្នះអ្នកប្រាជ្ញស្រុកអាយនេះទេ បើដូច្នេះត្រូវលេងខាងបញ្ជាក្រៅៗទីញុះចុះ គិតហើយក៏ចេញមកពហោត្រៃនោះ ហើយឲ្យទូលព្រះចៅក្រុងស្រីអយុធ្យាថា ឲ្យស្តេចចាត់អ្នកប្រាជ្ញមកចោទឆ្លើយគ្នាជាបញ្ជាទៅហានក្រៅនៅខាងក្រៅ ក្នុងទៀលនេះ។ ឯព្រះចៅស្រីអយុធ្យា ក៏ឲ្យចៅធនញ្ជ័យក៏ចេញទៅតទល់នឹងគេខាងក្រៅ។ ចៅធនញ្ជ័យក៏ទទួលអាជ្ញាចេញទៅទីខាងប្រជុំជន នឹងចោទឆ្លើយបញ្ជានោះ។ ឯព្រះចៅស្រីអយុធ្យា កាលធនញ្ជ័យចេញទៅតទល់នាខាងក្រៅនោះ ស្តេចចង់ជ្រាបអាថ៌សេចក្តីបញ្ជាដាច់ទើបត្រាស់ប្រើអមាត្យម្នាក់ឲ្យទៅស្តាប់បញ្ជា។ ឯអមាត្យនោះទៅនង់ចាំស្តាប់មើលជាអ្នកប្រាជ្ញខាងណាថាដូចម្តេចខ្លះ

ចោទឆ្លើយគ្នា តើយ៉ាងណាខ្លះ។ ឯអ្នកប្រាជ្ញទាំងពីរខាងដល់ពេលក៏ទៅដើងប្រជុំចោទឆ្លើយគ្នាតាមសញ្ញា អ្នកប្រាជ្ញលង្កាជាអ្នកចោទ កាលចោទនោះប្រើបញ្ជាគ តំលើកដៃទាំងពីរទៅដ៏ឱបជុំទីញ្ជ ហើយបង្ហាញទៅចៅធនញ្ជ័យឲ្យទាយ។

ឯចៅធនញ្ជ័យ ឃើញហើយ ក៏លើកំភួនដៃ១ បង្ហាញទៅទីញ្ជ, ឯអ្នកប្រាជ្ញលង្កាក៏ចូលចិត្តថាធនញ្ជ័យទាយត្រូវហើយ ទើបលើកម្រាមដៃ១ ទៀងបង្ហាយញ្ជទៅទៀត, ចៅធនញ្ជ័យក៏លើកម្រាមដៃទាំងអស់ទៀង ហើយលោះថយម្រាមកូនដៃ១ចេញ, អ្នកប្រាជ្ញលង្កា ក៏ចូលចិត្តបានក្នុងបញ្ជានោះ, ទើបឲ្យទាយតង ឃ្លោះគោះភេរីហ៊ោ ឲ្យសព្ទសាធុការដល់ធនញ្ជ័យ មានសេចក្តីកោតខ្លាចបញ្ជាធនញ្ជ័យ មិនអាចដើមញ្ជីនឹងចោទអាថ៌បញ្ជាតទៅទៀតទៀយ។

ឯអមាត្យម្នាក់ ដែលស្តេចប្រើឲ្យទៅចាំស្តាប់មើលអាថ៌បញ្ជានោះ លុះឃើញអ្នកប្រាជ្ញទាំងពីរចោទឆ្លើយគ្នា តែនឹងដៃតទៅទីញ្ជទៅមកដូច្នោះ មិនចូលចិត្តសេចក្តីថាជាអ្វី ចង់ដឹងសេចក្តីណាស់នឹងរាលរត់ទៅក្រាបទូលព្រះចៅផែនដីឲ្យជ្រាបមុន យកក្តីគាប់មុនគេ លុះឃើញចៅធនញ្ជ័យដើរចេញមក ក៏

សាកសួរថា "នែធនញ្ជ័យ, ទ្បើងបញ្ហាដែលអ្នកប្រាជ្ញលង្កាលើកដៃឱបដង្កិវិញនោះ តើអធិប្បាយសេចក្តីដូចម្តេច? ឯខាងអ្នកឯកលើកកំភួនដៃតទៅនោះ តើមានសេចក្តីដូចម្តេច? មួយទៀតខាងគេលើកម្រាមដៃ១បង្ហាញមក, ខាងអ្នកឯងលើកម្រាមដៃទាំង៥ តទៅគេវិញនោះ តើអធិប្បាយសេចក្តីដូចម្តេច?"។

ឯធនញ្ជ័យ បានឮអមាត្យនោះសួរអាថ៌ដូច្នោះក៏យល់សេចក្តីថា ចៅនេះបើបានដឹងអាថ៌បញ្ហានេះហើយគង់នឹងទៅក្រាបទូលយកគាប់ មុនអញមិនខានបើដូច្នេះ អញនឹងប្រាប់ឲ្យខុសអំពីអាថ៌បញ្ហានេះចេញឲ្យបានក្តីខ្មាសនាកណ្តាលដំនុំព្រះចៅជាម្ចាស់ គិតហើយធនញ្ជ័យក៏ប្រាប់ទៅថា "ឯអ្នកប្រាជ្ញលង្កាដែលឱបដៃដង្កិវិញនោះ គឺគេសួរយើងថាអង្រុត១ តើទុតបានត្រីប៉ុន្មាន? យើងលើកភំភួនដៃប្រាប់ទៅនោះ គឺថាបានត្រីវ័ស់១ រួចគេលើកចង្កួលដៃទ្បើងទៀត គឺគេសួរថា ត្រីវ័ស់១ បើធ្វើជាដៀត តើបានប៉ុន្មានចំនៀក?, យើងលើកម្រាមដៃទាំង៥ បង្ហាញទៅវិញនោះ គឺថាបាន៥ ចំនៀក"សេចក្តីយ៉ាងនេះឯងចូរចូលចិត្តចុះ"។

ឯអមាត្យនោះជាមនុស្សឥតសតិបញ្ញា និងត្រិះរិះឲ្យល្អិតល្អ

គ្រាន់តែឮចៅធនញ្ជ័យប្រាប់ដូច្នោះហើយក៏រត់ម្ចាស់ចូលទៅកាន់ព្រះរាជទ្រង់ជ័យ។ ឯព្រះចៅផែនដីយល់ហើយក៏ត្រាស់សួរថា "ម្តេចទៅវ៉ុយ អ្នកប្រាជ្ញយើង តើស៊ូនឹងគេបានឬទេ? មួយសោតបញ្ហាដែលគេចោទឆ្លើយគ្នានោះ តើមានសេចក្តីយ៉ាងណាខ្លះ?"។ ឯអមាត្យនោះក៏ក្រាបទូលអាថ៌បញ្ហាតាមពាក្យធនញ្ជ័យប្រាប់នោះ សព្វប្រការ។ ឯបរមក្សត្រាធិបតី បានស្តាប់ពាក្យអមាត្យនោះទូលដូច្នោះហើយ ក៏ត្រាស់ថា "បញ្ហាអ្វីនឹងយាយពីអង្រុតនុតត្រីធ្វើដៀតដោងដូចជាប្រដៅកូនក្មេង ទាំចោទគ្នាលេងដូច្នោះ ក៏ឯអ្នកប្រាជ្ញកោះលង្កានោះល្ងីថាខ្លួនចេះដឹងក្នុងគម្ពីរសាស្ត្របាលី ដឹងហេតុលោកិយលោកា គួរតែសម្តែងពីគតិលោកប្តូតិធម៌ ជាអាថ៌សុខុមគម្ពីរភាពនោះ ទើបគួរសមជាអ្នកប្រាជ្ញរាជបណ្ឌិតបាន នេះហេតុអ្វី ទៅយកទ្បើងអង្រុតថ្លងមកចងជាបញ្ហាចោទឆ្លើយគ្នាយ៉ាងនេះ, នែអមាត្យ បញ្ហានោះក្រែងមិនដូចឯងយកមកសម្តែងនេះទេដឹង?"។

អមាត្យទូលថា "ពិតមែន ព្រោះបានសាកសួរផ្ទាល់នឹងធនញ្ជ័យនោះប្រាកដហើយ"។ ឯចៅធនញ្ជ័យកាលសម្រេចកិច្ចចោទឆ្លើយនោះហើយ ក៏ទៀបអាត្មា ចូលទៅគាល់មហាក្សត្រនាចុង

ព្រះរាជនោង។

ឯមហាក្សត្រធិបតី យល់ថាធនញ្ជ័យមកគាល់ព្រះអង្គដូច្នោះ ក៏ត្រាស់សួរថា "អើធនញ្ជ័យ ទ្បើងបញ្ហាដែលអ្នកប្រាជ្ញលង្កាគេឱ្បនដំដែ ហើយចៅឯងលើកកំភួនដែតតបទៅនិញ្ចឹនោះ មានអាថ៌សេចក្តីដូចម្តេច? មួយទ្បៀត ខាងគេលើកម្រាមដែ១ ទ្បើងហើយចៅឯងលើកម្រាមដែទាំង៥ តតបទៅនិញ្ចឹនោះ តែមានសេចក្តីដូចម្តេច? ចូរចៅអធិប្បាយទៅមើល!។ ឯធនញ្ជ័យក៏អធិប្បាយថ្វាយសេចក្តីថា "អ្នកប្រាជ្ញលង្កាលើកដែដំដុំនិញ្ចឹនោះ គឺចោទថា ក្នុងចក្រវាលយើង១ នេះមានមានភ្នំជាទីតាំងសម្រាប់លោកតែប៉ុន្មាន?, ទូលព្រះបង្គំជាខ្ញុំលើកកំភួនដែនោះ គឺប្រាប់គេថាមានភ្នំព្រះសុមេរុ១ ជាធំជាទីតាំងសម្រាប់លោកយើងនេះដល់ក្រោយគេលើកម្រាមដែ១ ទ្បើងនោះគឺគេចោទថា ក្នុងភទ្ទកប្បយើង១នេះ មានព្រះពុទ្ធត្រាស់ប៉ុន្មានព្រះអង្គ? ទូលព្រះបង្គំជាខ្ញុំលើកម្រាមទាំង៥ទ្បើងឆ្លើយទៅថា មានព្រះពុទ្ធត្រាស់៥ព្រះអង្គ, ទូលព្រះបង្គំជាខ្ញុំលោះម្រាម១ ចុះប្រាប់ថាព្រះពុទ្ធត្រាស់បាន៤ព្រះអង្គទៅហើយ នៅសល់១ព្រះអង្គ គឺព្រះអរិយមេត្រី ព្រះអង្គពុំទាន់ចុះមកត្រាស់, សេចក្តីចោទ

ឆ្លើយគ្នានោះមានសភាពយ៉ាងដូច្នេះសូមទ្រង់ជ្រាប"។

ឯព្រះចៅ ស្រីអយុធ្យាបានទ្រង់ព្រះសណ្តាប់សំពុំអាថ៌បញ្ហានោះហើយ ស្តេចកក៏មានព្រះរាជហប្ញទ័យត្រេកសោមនស្សត្រាស់ថា "អើសេចក្តីបញ្ហាយ៉ាងនេះទើបសមគួរ ជាគតិលោកគតិធម៌បាន, ត្រូវទំលំអានជាតិបណ្ឌិតគប្បីពោលហើយ, ចុះអមាត្យនេះគេចេះពីណាមក បានជាមកប្រាប់យើងថាទៅជាអង្រុតទុតត្រឹមធ្វើជាដៀត៥ ចំទ្បើកផ្តើសផ្តាសដូចជាប្រដៅកូនក្មេង តង្វាលក្របីទាចោទគ្នាលេងនោះ សមគួរឬជាពាក្យអ្នកប្រាជ្ញបំណាច់មកពីកោះលង្កា លុះថាជាអ្នកចេះគតិធម៌គតិលោក ទៅយោគយកទ្បើងអង្រុតថ្នងមកជាបញ្ហានោះ គេមានព្រឹលកាលឯណាទាព្រឹលឯអមាត្យឯងនេះ ចេះមកកាច់មួលពាក្យគេតែផ្តាសសោះជាម្តង ",ស្តេចត្រាស់ហើយក៏ទ្រង់ព្រះរាជទានមាសប្រាក់ តែកទឹកង សំពត់អាទិសៀ ឲ្យចៅធនញ្ជ័យបណ្ឌិតតាមក្តីគាប់។

ឯអមាត្យនេះ ត្រូវទ្បើស្តេចបន្ទោសបានសេចក្តីខ្មាសគេ នាកណ្តាលជំនុំធំ គឺតខឹងនឹងចៅធនញ្ជ័យ ជេរពោលតែក្នុងពោះថាខ្មោចអាព្រឹលយ៉ាងនេះ ទាចង់ថាដូចម្តេចក៏ថាទៅ ធ្វើឲ្យអញ

បានសេចក្តីខ្មាសគេ នាកណ្តាលប្រជុំជនយ៉ាងនេះ ។

ចប់រឿងបញ្ហាដៃ

រឿងអមាត្យព្រះបាទពិម្ពិសារនិង អជាតសត្រូវនិងកុមារ

សេចក្តីក្នុងរឿងធនញ្ជ័យ មានអាថ៌បញ្ហាពិស្តារទៀត នៅមានច្រើនណាស់ ក្នុងទីនេះយើងទាញយកតែបញ្ហា១នេះ មកសម្តែងឲ្យឃើញសេចក្តីថា អ្នកប្រាជ្ញមានបញ្ញាហើយ អាចដឹងអាចស្គាល់ក្នុងអាការលើកដៃ ឱបដៃ ឬឃើញតែកិរិយាក្រៅរបស់អ្នកដទៃក៏អាចដឹងសេចក្តីនោះបាន ។ មួយទៀតអ្នកមានបញ្ញានោះប្រៀបដូចប្រទីបបំភ្លឺ ឆ្លុះមើលនូវទីងងឹតទីកំបាំងបាន ។ មួយទៀតអ្នកមានចំណេះវិជ្ជាសព្វសរពើហើយតែបើពុំមានបញ្ញានឹងពិចារណាត្រិះរិះ តាមសម័យផងសព្វវិជ្ជានោះក៏ពុំអាចទុងទៀងថ្លាទៅបាន លុះតែមានបញ្ញាសតិសម្បជញ្ញៈផង ទើបធ្វើសព្វវិជ្ជានោះ ឲ្យទុងទៀងទៀងបាន មានទឹនាប្រៀបដូចយ៉ាងរាជអមាត្យព្រះបាទពិម្ពិសារទាំង៣ពួកនោះឯង ។

ដំណើរថា កាលព្រះអជាតសត្រូវរាជកុមារស្តាប់ពាក្យទេវទត្តនោះ ញុះញង់ឲ្យសម្លាប់ព្រះបាទពិម្ពិសារជាព្រះរាជកុមារសៀតកាំបិតគ្រឿងប្រហារចូលទៅក្នុងព្រះរាជវាំង ដើម្បីនឹងពិឃាតព្រះវរនាជបិតា ។ ឯពួករាជអមាត្យនាយតម្រួតរក្សាអង្គ បានឃើញព្រះរាជកុមារចូលក្នុងព្រះមន្ទីរខុសកាលដូច្នោះ ក៏ហាមឃាត់មិនឲ្យចូល ឯព្រះរាជកុមារចេះតែចេសចូលទៅ ទើបនាយតម្រួតនាំគ្នាចាប់ត្រួតមើលក្នុងអង្គកាយ បានឃើញកាំបិតគ្រឿងប្រហារព្រះរាជកុមារសៀតមកដូច្នោះ ក៏ចាប់ចងដាក់ទោសតាមរាជបញ្ញត្តិ ហើយនាំគ្នាពិភាក្សាទោសព្រះរាជកុមារៗក៏ឲ្យការតាមខ្លួនគិតសម្លាប់បិតានោះ ។ ឯនាយតម្រួតទី១ឆ្លើយទៀងថា "ទោសកប្បតិនេះត្រូវសម្លាប់ព្រះរាជកុមារផង ត្រូវសម្លាប់ព្រះទេវទត្តនេះ និងលោកសង្ឃបណ្តាជាពួកគប់គិតចូលគំនិតគ្នាទាំងអស់ផង" ។ ឯនាយតម្រួតទី២ឆ្លើយទៀងថា "ទោសកប្បតិនេះត្រូវសម្លាប់តែព្រះរាជកុមារនឹងព្រះទេវទត្តនេះ ទើបគួរ, ឯបណ្តាលោកសង្ឃឯទៀតៗនោះមិនត្រូវសម្លាប់ទេ ព្រោះលោកពុំបានដឹងឮផង" ។ ឯនាយតម្រួតទី៣ជាមន្ត្រីមានសតិសម្បជញ្ញៈឆ្លើយទៀងថា "លោកអ្នកទាល់គ្នាកាត់

ទោសយ៉ាងនេះមិនត្រូវទេ, ឯទោសនេះបើរូបអ្នកដទៃឯទៀត
នោះគួរហើយ តែនេះព្រះរាជកុមារជាព្រះរាជបុត្រារបស់លោក, ព្រះទេវទត្តសោតជាវង្សាគក្យបុត្តិយ៍ព្រះចៅជាម្ចាស់ក៏នាប់
អានគោរពប្រតិបត្តិ យើងនឹងកាត់ទោសពីឃាតឯងថា កាចឯណា
បាន ទោសនេះហួសវិស័យយើងជាមន្ត្រីពិភាក្សា គួរតែនាំគ្នា
ទៀងក្រាបទូលឲ្យទ្រង់ជ្រាប បើជាទ្រង់ព្រោសយ៉ាងណា?
ក៏តាមតែព្រះអង្គលោកចុះ ព្រោះកូនគេ អាពុកគេថាយ៉ាងណា
សឹមយើងធ្វើតាមជាក្រោយ"។ ឯនាយតម្រួតទាំង៣ពួក ពិគ្រោះ
គ្នាយើញផ្លូវវៀងខ្លួនយ៉ាងនេះទើបនាំគ្នាចូលទូលព្រះបាទពិម្ពិ
សារាជបិតា តាមដំណើរដែលព្រះអជាតសត្រូវកុមារ ប្រតិបត្តិ
ការខុសប្រពៃណី កន្លងព្រះរាជបញ្ញត្តនោះសព្វប្រការ។
ឯព្រះបាទពិម្ពិសារស្តេចជ្រាបហើយ ទើបត្រាស់ថា "អើទោស
យ៉ាងនេះ អ្នកទាំងឡាយពិភាក្សាទៅ តើយល់ដូចម្តេច?។

ឯអមាត្យទាំង៣ ពួក ក៏ក្រាបទូលតាមដំណើរដែលខ្លួនគិត
យល់ផ្ទេរៗគ្នានោះឯង ទើបព្រះរាជពិម្ពិសារាជស្តេចទ្រង់ត្រាស់ថា "អើពួកនាយតម្រួតទី១ ពិភាក្សាថា ត្រូវឲ្យសម្លាប់ទាំង
ព្រះទេវទត្តនឹងព្រះសង្ឃទាំងពួង ព្រមទាំងព្រះរាជកុមារ

ដែងនោះពាក្យនឹនិច្ឆ័យនោះយល់កើនហួសណាស់ ត្រូវឲ្យដកជាន
បន្តយយសសក្តិ ក៏ឯអមាត្យទី២ ពិភាក្សាថា ត្រូវឲ្យសម្លាប់ព្រះ
រាកុមារ ព្រមទាំងព្រះទេវទត្តត្នេរនោះ ពាក្យនឹនិច្ឆ័យនោះ
ត្រូវបន្តយប្រាក់ខែបៀវត្សឯអមាត្យទី៣ ពិភាក្សាថាត្រូវ
ទៀងក្រាបទូលសិននោះ ពាក្យនឹនិច្ឆ័យនោះ ត្រូវឲ្យទៀងយស
សក្តិប្រាក់ខែបៀវត្សថែម ព្រោះជាអ្នកមានសតិសម្បជញ្ញៈ
ចេះពិចារណាត្រូវតាមវត្ថុ តាមសម័យកាល"។

ទៀងនិទានេះ មានសេចក្តីពិស្តារនៅក្នុងព្រះគម្ពីរសុត្តន
បិដកឯណោះ ឯងស្តាប់មើលចុះ លោកអ្នកមានសតិសម្បជញ្ញៈ
ពិចារណាមើលវត្ថុមើលសម័យកាលគួរដល់កាលនេះសឹងចំនែន
ទ្លូវយសសក្តិបរិបូណ៌បាន អ្នកមានសតិស្មារតីនេះ មិនដែលភ្លាត់
ភ្លើទៅក្នុងការភ្នាក់ងារដែលខ្លួនធ្វើ គឺនឹងដើរក្តី អង្គុយក្តី ដេក
ក្តី ឈរក្តី ឬលើកដៃ លើកជើង លាតបត់ដៃបត់ជើងក្តី ឬបរិ
ភោគភោជននាហារជាវត្ថុទន់ឬរឹងក្តី កាលទំពាស៊ីកាលលេបចូល
ទៅក្នុងពោះក្តី តែបើពុំមានសតិស្មារតីនឹកជាមុនហើយ ការអស់
នោះសឹងភ្លាត់ទៅផ្ទេរៗមានដួលប៉ះត្រូវបន្លាជាដើម បើខា
ឯបរិភោគជីកស៊ីសោត មានស្លាក់ឆ្អឹងត្រី ត្រូវម្ទេសហឺរជាដើម

អ្នកគ្មានសតិបញ្ញានោះ លោកថា ជាមនុស្សប្រកាន់សេចក្តីប្រមាទមួយនេះ មាននៅលើបុគ្គលណាហើយបុគ្គលនោះនឹងតាំងខ្លួនឲ្យមាំមួនពុំបាន បើធ្វើការអ្វីការនោះខូចបងវិញ, ដូចនិទានស្បៀនកាន់ភ្នាក់ងារនក្បាលើរាជការបស់ព្រះបាទពិម្ពិសារនាជនោះឯង ។

ទើងព្រះធនិយថេរនិងនាយសមុហបញ្ជី

ទើងនោះមានសេចក្តីថា កាលណោះមានព្រះមហាថេរ១អង្គឈ្មោះព្រះធនិយថេរ ជាកូនអ្នកស្មូនឆ្នាំង ថ្ងៃ១ព្រះថេរនោះទៅឆយកឈើរាជការអំពីនាយសមុហបញ្ជីថា បណ្តាយឈើព្រៃព្រឹក្សាលតាវល្លិទាំងឡាយនោះ ព្រះបាទពិម្ពិសារនាជស្តេចទ្រង់ព្រះសទ្ធាបានទៀងថ្វាយ ដល់ព្រះភិក្ខុសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រធានហើយ ឥឡូវនេះអាត្មាភាពត្រូវការឈើធ្វើកុដិចូរអ្នកឯងចាត់ចែងឈើគ្រឿងទព្វសម្ភារៈអស់នេះ ដល់អាត្មាភាពចុះ ។

ឯនាយសមុហបញ្ជីនោះ ជាមនុស្សពុំមានសតិសម្បជញ្ញៈពិចារណាឲ្យយល់ការថា ឈើនេះគឺតែកាប់ចាំងអារកាត់ ជាគ្រឿងទព្វសម្ភារៈស្រេច ជារបស់រាជការត្រូវការ, មួយទៀត

សូម្បីនឹងមានសំបុត្រ១ច្បាប់ដំរាបសួរទៅដល់មហាមាត្យជាធំឲ្យក្រាបទូលថាឈើនោះ ឥឡូវលោកសង្ឃមកយកទៅធ្វើកុដិជាទ្រង់ប្រគេនឬម្តេចយ៉ាងនេះពុំមាន និមិត្តតែព្រះធនិយថេរមកឆដូច្នោះ ក៏ឆោតតាម លើកយកឈើអស់នោះឲ្យទៅព្រះធនិយថេរ ដោយអំពើចិត្តឥតពិគ្រោះ ។ ឯព្រះធនិយថេរក៏ដឹកនាំយកឈើនោះទៅ ធ្វើកុដិតាមសេចក្តីប្រាថ្នារបស់ខ្លួន ។

លុះនៅមក នាយជាងចៅភ្នាក់ងារធ្វើរាជការជួសជុលព្រះរាជតំណាក់ អស់ឈើនឹងធ្វើតទៅទៀតទើបដំរាបដល់មហាមាត្យ ។ ក៏ឲ្យចៅភ្នាក់ងារទៅនាំយកឈើនោះ ។ ឯនាយសមុហបញ្ជីក៏តបមកថា ឈើអស់នោះពុំមានទេ ដ្បិតព្រះធនិយថេរលោកមកយកទៅធ្វើកុដិផុតអស់ហើយ ។

ពាក្យអស់នោះពុំស្ងាត់ ក៏ឮជ្រាបដល់ព្រះបាទពិម្ពិសារនាជ ។ សេចទ្រង់បន្ទោសនាយសមុហបញ្ជីជានាយស្បៀននោះជាអនេកបរិយាយផ្សេងៗហើយទ្រង់នាំហេតុនោះ ទៅឯក្រាបបង្គំទូលព្រះសម្មាសម្ពុទ្ធជាម្ចាស់ តាមទើងព្រះធនិយថេរទៅឆយកឈើរាជការមកធ្វើកុដិ ។

ទើបសម្តេចព្រះជិនស្រីទ្រង់យកទត្តិទាននោះជាបឋម

អទិន្នាទានបារាជិ បញ្ញត្តសិក្ខាបទអទិន្នាទានបារាជិកដល់ភិក្ខុ
ទាំងឡាយក្នុងព្រះពុទ្ធសាសនាតមក ។

ទ្បើនេះមានសេចក្តីពិស្តារនៅក្នុងគម្ពីរព្រះវិន័យបិដកឯ
ណោះ គួរបួលចិត្តចុះ ។ ក៏ឯទ្បើងនិទានបុគ្គលមានបញ្ញាចេះពិ
ចារណាមើលដ៏ទិញ្ញនោះ សឹងចំទើនទុងទ្បើងបាន ដូចនិទាននា
យតម្រួតទី៣ ដែលទីនិច្ឆ័យទ្បើងក្តីព្រះអជាតសត្រូវជាវាជកុមារ
នោះឯង ។

បណ្ឌិតវគ្គោ និដ្ឋិតោ

ទ្បើងបណ្ឌិតវគ្គនេះមានវត្ថុនិទាននៅច្រើនណាស់យើងពុំឈ្លុះ
នឹងពណ៌នាឲ្យពិស្តារទៅបាន សំដែងមកតែប៉ុណ្ណោះ ជានិយសដ្ឋេ
បទុកជាបែប ឲ្យចៅឯងគិតមើលជាគតិលោកយោគទៅតាម
ហេតុដែលកើតទ្បើងមានទ្បើងតទៅខាងមុខទៅតចុះ ។

ក្នុងបណ្ឌិតវគ្គ សន្ទុតចប់តែប៉ុណ្ណោះហោ

បងអើយបណ្ឌិត លោកត្រិះរិះគិត អាការនាក់ជ្រៅផ្លូវណា
ចម្រែន ក្រទើនត្រាច់ទៅ ផ្លូវណាមិនត្រូវ មិនត្រាច់ទៅត្រាច់ ។
ហេតុណាកើតផល ផលណាមកពាល់ ប្រាជ្ញប្រៀបផ្ទំសាច់ ឆ្អុះ
កិច្ចឈ្លេចកល យល់មួលរំពេច សតិមិនភ្លេច មិនភ្លាត់តាមភ្លើន ។

កូនសិស្សសួរត្រូថា សូមទានទ្បើងគតិពាលគតិប្រាជ្ញ "ពាល
នាំឲ្យកាច ប្រាជ្ញនាំឲ្យស្លូត" នោះខ្ញុំចូលចិត្តហើយ តែគតិមនុស្ស
ឆោតល្ងង់នោះ ក្តីឃ្លានបាយ ឃ្លានមាន ឃ្លានស្រទ្បាញ់៣ ប្រការ
នោះលោកគ្រូអធិប្បាយពុំទាន់ពិស្តារ ។ ក៏ឯកិរិយាឆោតនោះ
អ្នកខ្លះពុំមានក្តីឃ្លាន៣ ប្រការនោះទេ តែនៅឆោតក៏មាន
សូមទានអធិប្បាយតទៅទៀត" ។

ត្រូតបថា "សេចក្តីឆោតប៉ុន្មានៗនោះនៅរួមក្នុងគតិគ្មាន
សតិសម្បជញ្ញៈនេះឯង អ្នកគ្មានសតិបញ្ញានឹងពិចារណាមើល
ហេតុ មើលបច្ច័យ មើលចុងមើលដើមផ្ទុំហេតុប្រៀបផលឲ្យ
ដល់គ្នាហើយ អ្នកនោះនៅក្នុងឆោតមិនលែង" ។ យើងសួរឯង
ទិញ្ញ បញ្ជាថាអ្វីដែលជ្រៅក្រៃលែងជ្រៅ, អ្វីនាក់ក្រៃលែងនា
ក់នោះ ចូរឯងសំដែងទៅមើល? ។

កូនសិស្សតបថា "ជ្រៅក្រៃលែងជ្រៅនោះ បានដល់ខាង
ព្រះញ្ញាណព្រះពុទ្ធ ឬព្រះសទ្ធម្មគម្ពីរភាព, ឯនាក់ហើយក្រៃលែ
ងនាក់នោះបានខាងបញ្ញាកូនក្មេង" ។

ត្រូឆ្លើយថា "អើ បញ្ញាកូនក្មេងតូចដូចទឹកនាក់ពិត, ក៏ឯជាតិ
ទាំងឡាយ បញ្ញានៅនាក់សតិសម្បជញ្ញៈនៅពុំទាន់កើតទ្បើង

ក្តាហាន ទើបានទៅឆោត ឯងស្តាប់មើលចុះ ជាតិទាវកដែលយំ
កាលណោ ចាស់ៗ លោមបញ្ឆោតថា អាវ៉ាកុំយំចាំម៉ែទៅវាយអា
នោះឲ្យមេនោះឲ្យ ជួនណាថាស្តោះទឹកមាត់លើបាតដៃ សឹមម៉ែ
វាយឲ្យ ជួនណាបញ្ឆោតថា កុំយំខ្លាចទឹងមោងវាមកខាំ, ជួនណា
ថាកុំដេកនៅលើគេ ក្រែងតាព្រេងចាក់ទឹកបាយ លើកឡាល
ជួនណាថា កុំលេងអង្កូរវាមុខទឹង, ចាស់ៗបញ្ឆោតយ៉ាងនេះជា
ដើម។ ឯទាវកគ្មានសតិសម្បជញ្ញៈយ៉ាងនេះ ទើបឆោតឲ្យចាស់
ៗបញ្ឆោតបាន។ ជាតិមនុស្សទាំងឡាយដែលឆោតនោះ
ព្រោះពុំមានសតិសម្បជញ្ញៈដូចទាវកនោះឯង។ ក៏ឯក្តីឃ្លាន ក្តី
ប្រាថ្នារបស់មនុស្សនោះ ជាផ្លូវទៀឲ្យអាពាលវាបញ្ឆោតបាន ដូច
បានសំដែងមកហើយ ក្នុងពាលវគ្គខាងក្រោយ។

មួយទៀតមនុស្សឆោតនោះ ព្រោះពុំស្គាល់លោកធម៌ទាំង៨
ប្រការគឺៈ លាភ១ អលាភ១ យស១ អយស១ សុខ១ ទុក្ខ១
សរសើរ១ និន្ទា១ ធម៌៨ ប្រការនេះជាធម៌របស់លោក សត្វលោ
កសឹងវិលទៅតាមធម៌ទាំង៨ ប្រការជាប្រក្រតី ក្តីលោភ ក្តីឃស
សក្ការៈ ក្តីសុខសម្រាន្ត ក្តីសរសើរតំកើងតំកល់ធម៌៤ប្រការនេះ
សត្វលោកប្រាថ្នាចង់បាន។

ឯក្តីអលាភគឺខាតលាភ ក្តីអយសគឺថយយសសក្តា ក្តីទុក្ខរំខាន
ក្តីនិន្ទាគរហាតិះដៀល ធម៌៤ប្រការនេះ សត្វលោកសឹងស្អប់
សឹងខ្ខើមពុំចង់បានឡើយ, តែនឹងគេចកែរត់ឲ្យផុតចេញទៅ
ពុំបាន ទោះជាមិនចង់បានក៏ចង់បានដដែល ព្រោះសភាវធម៌ជា
គូៗនឹងគ្នា បុគ្គលណាប្រាថ្នាតែលាភ យល សុខ សរសើរ ចំណែក
១ ធ្វើម្តេចនឹងបានធម៌៤ យ៉ាងនេះស្តិតស្ថេរនៅជាប្រក្រតីបាន
សភាវធម៌៨ ប្រការនេះជារបស់សម្រាប់លោក លោកតែងវិល
ទៅតាមធម៌៨ ប្រការនេះឯង។

បុគ្គលណាប្រាថ្នាតែលាភ យស សុខ សរសើរ៤ ប្រការនេះ
ហើយ តង់នៅក្នុងឆោតមិនលែងទៀឡើយ, ឯងស្តាប់មើលចុះ វឿ
ងត្រូកណ្តាញ់នៅស្រុកមាត់ជ្រូក១ ត្រូហមជើងបាក់ នៅស្រុក
មង្គលបូរី លឿដល់ស្រុកបាត់ដំបង១ ត្រូបង់បទ១ ត្រូអស់នេះ
អាអ្នកលេង ទាក្លែងតែងកលខ្មាយផ្ញាយពាក្យអួតថា ពូកែ
ឆុតឆាប់ អាចរម្ងាប់សព្វទោគអ្នកនគរបាន។

ឯអ្នកនគរណាលុះអំណោចធម៌៤ យ៉ាងខាងលើហើយ សឹងដំផ្លែ
លតឹកកងនាំគ្នាយកទៀនធូបប្រាក់កាសដួលកប៉ាល់ជិះទៅទក
ត្រូពូកែនោះ។ ពួកចិននាយកប៉ាល់បានប្រាក់ថ្លៃកប៉ាល់ក៏..

បនិបូណ៌ កាលអ្នកនគរត្រូវទិការទៅស្រុកមាត់ជ្រូក ក្នុងកាលនោះ
ឯង។

មួយទៀតមានទឹកបឹងទី១ នៅខែត្រស្រុកទឹកជោរកាលនោះ
មានក្របីឈឺភ្នែក១ ទាំចុះទៅត្រាំទឹកបឹងនោះវ្យើយៗលុះយូរ
ថ្ងៃមក ភ្នែកក្របីនោះជាឡើងដូចប្រក្រតីៗឯអ្នកស្រុកនោះ
ឃើញក្របីនោះជាភ្នែកហើយក៏តឹតសេចក្តីថ្លើថា ទឹកបឹង
នោះពូកែ នាំគ្នាទៅងូតទៅដងយកមកផឹក តើតមានត្រើឯង
សក្ការបូជាអុជទៀនធូបបូជាទឹកបឹងនោះ ក៏ត្តិសព្ទក៏ឮខ្ទរខ្ទាយ
សុសសាយដល់អ្នកស្រុកសៀមរាប់ ស្រុកបាត់ដំបង តើតថ្លើនាំ
គ្នាទៅបូជាសូមទឹក យកទឹកនោះ ជាកោលាហល ដល់ជ្រាបទៅ
លោកនាជការៗ ឲ្យទៅហាម ឃាត់បណ្តាពួកនាស្តួឆោតទាំង
នោះ។

មានទៀងមួយទៀត តឹមានដើមដង្កោ១ដើមនលើងប្ញសនលំ
ច្រងចុះដល់ដី នៅមកជាយូរខែ អ្នកស្រុកដើរទៅមក ក៏បានដល់
តែនាល់គ្នា ថ្ងៃមួយមានចៅម្នាក់ទៅកាប់ចុងមែកដង្កោនោះចេ
ញខ្លះ ឯដើមដង្កោនោះ កាលតែកាប់ចុងស្រាលចេញហើយ ក៏
ដើបទ្បើងដោយកម្លាំងប្ញសទាញបន្តិច។

ឯអ្នកស្រុកបានឃើញដើមដង្កោនោះហើយ ក៏ចូលចិត្តថ្លើ
ថាពូកែ ទើបនាំគ្នាយកទៀនធូបទៅអុជបូជាសូមស្មោះសម្បក
យកជាថ្នាំកែរោគផ្សេងៗ អ្នកខ្លះកាត់យកប្ញសយកមែកធ្វើជា
ថ្នាំ ជាកូនសង្កត់ចងដៃចងចងក្តោះផ្តាសទៅ, ឯដើមដង្កោនោះត្រូវ
អ្នកស្រុកស្មោះសម្បកអស់រលស់ជាតិផែនដីផ្សាយមិនដល់ចុង ក៏
នៅសន្ធូបកាយតាយហោងបង់។

មានទៀងមួយទៀត តឹអ្នកស្រុកនៅទិសខាងលិចថ្ងៃ១ មាន
គោខ្មៅក្មេងស្ទាវ១ ជារបស់អ្នកឯណាពុំដឹង គោនោះដើរទកស្តុ
ទៅតាមហ្វូងទាំ។ ឯអ្នកស្រុកឃើញគោខ្មៅនោះរូបល្អ ក៏សំគា
ល់ថា ព្រះគោរត់មកអំពីស្រុកសៀម ទើបនាំគ្នាដេញចាប់ក៏
ពុំបានអ្នកខ្លះរត់តាមពីក្រោយ ស្រែដង្ហោថា ព្រះអង្គម្ចាស់អើយ
ឈប់ប្រោសសត្វដែលខាត់ក្រ អ្នកខ្លះបានចេកទុំ បានស្មៅ ស្រូវ
រត់តាមទៅឲ្យគោៗនោះមិនឈប់នៅ ចេះតែទៅតាមកម្លាំង
ទាំ។

ឯបណ្តាអ្នកស្រុកទាំងប្រុសស្រី នាំគ្នាទ្បៀបត្រើឯងបូជា
ផ្សេងៗហើយត្រាច់ទៅតាមគោនោះឯង, ឯគោនោះលុះឃើ
ញមនុស្សតែមកចោមជុំខ្លួន នឹងរកចន្លោះច្រកបោលចេញពុំ

ទួចដូច្នោះ ក៏ដាលបោលសម្រុកពាសត្រង់មកជំនុំមនុស្សច្រើន
មនុស្សទាំងឡាយក៏ផ្អើលរត់ច្រៀតដែកគ្នាទៅទីទែៗ អ្នកខ្លះ
ដួលបែកដៃបែកជើង អ្នកខ្លះដួលផ្កាប់មុខកំពប់ទៀនធូបជិះ
ជាន់នៅលើគ្នា ដោយក្តីភ័យនឹងស្វែងគោនឹងក្របកជើងគោ។
នោះ បោលបោះផ្លោះកន្លងមនុស្សទួចចេញបាន ក៏បោលទៅ
រកហ្វូងវាដែលធ្លាប់នៅជាមួយគ្នាអំពីដើម។ ឯមនុស្សទាំងឡា
យបានក្តីទុក្ខទៀតនាពិការដៃជើងជាដើម ក៏នាំគ្នាវិញ្ញទៅស្រុក
វិញ។

ទៀងនេះចូលឯងស្តាប់មើលចុះ មនុស្សគ្មានសម្បជញ្ញៈ ត្រែះ
ទ្រេះឲ្យឃើញហេតុឃើញវត្ថុជាទីឯណោអាងបាន គួរឬ ទៅជឿ
ទៅបូជាសត្វតិរច្ឆានឲ្យបាននូវក្តីទុក្ខទៀតនាដូចពណ៌នាមកនេះ
ទាំងនេះក៏ព្រោះគ្មានសតិសម្បជញ្ញៈ ពិចារណាឲ្យឃើញដើម
ហេតុគឺគោនោះ តើជាគោមានជីវិតពិតដូចគោធម្មតា ឬ យ៉ាង
ណា កាលគោនោះនៅស្រុកខ្មែរយើងណាខ្លះ, កាលស្តេចនទេ
សូរទសៀមលើកទ័ពមកវាយស្រុកខ្មែរយើងគឺបន្ទាយលង្វែក
បែកបាននាំយកគោនោះ តើពីឆ្នាំណា? ពីចុះលួសកវាជប៉ុន្មាន?។
បើគឺតទៅតាំងអំពីឆ្នាំ វាជ្រុនទេសូរទវាយបន្ទាយលង្វែក ដល់មក

សម័យនេះ កន្លងទៅជាង២០០ ឆ្នាំទៅហើយ គោនោះនឹងរស់
នៅដល់ឥឡូវនេះម្តេចបាន គោឯណោអាយុវែងម្ល៉ះ!។

មួយបើគោនោះ ជាងគេធ្វើដោយថ្មឬដោយសំរឹទ្ធិរឹតត្រ
ដោយមាសដោយប្រាក់ទេ អើហេតុអ្វីគោរូបនោះ ម្តេចចេះ
បោល ចេះបរចរចេញរត់មកស្រុកខ្មែរវិញបាន។

មួយមានពាក្យព្រៃងថា គោនោះគឺសៀមគេយកទៅបោះ
ភ្ជាប់ជើងទាំង៤ ដោយដែកគោល យកច្រវាក់ចង់ក្រៀកដោយ
ជ្រុំវិញ ពុំឲ្យរត់ចេញទៅណាបាន ហើយហាមមិនឲ្យពួកខ្មែរ
យើងនេះ ចូលទៅមើលជិត ថាបើខ្មែរទៅជិតហើយ ក្រែង
ខ្មែរនិយាយជាភាសាខ្មែរ គោនោះកាលបើឮភាសាខ្មែរហើយ
ក៏កន្ត្រាក់លបម្រាស្រែកយំកងរំពងខ្លាំង។

ពាក្យព្រៃងនេះ ឯងស្តាប់មើលចុះ គួរឬគោសំរឹទ្ធិទេ ម្តេច
ចេះយំស្រែក ខាងសៀមសោត ម្តេចចាំទៅបោះដែកគោល
ចងក្រៀកនោះ ឆ្កួតឬ រូបគោសំរឹទ្ធិ (ពាក្យព្រៃងនេះមិនគួរ
នឹងជឿស្តាប់សោះ)។

ឯជាតិអ្នកកាន់គោជាព្រះនោះក៏មានខ្លះ ដូចយ៉ាងសាសនា
ព្រាហ្មណ៍ជំពូក១ គឺជាតិឥណ្ឌូធានីគេកាន់សាសនាឥសូរទនាវាយណ៍

ខ្លះកាន់សំពះយោនីនាងឱមាភគវតី, ខ្លះកាន់សំពះអង្គជាតិព្រះ
សយម្ភូ តីលិង្គព្រះឥសូរ, ខ្លះកាន់សំពះគោដែលជាយានរបសព្រះ
ឥសូរ, ពួកអស់នេះ សឹងមានសទ្ធាសាងព្រះវិហារតំកល់គោខ្មៅ
តាំងជាព្រះអង្គថាព្រះគោ នាំគ្នាយកអាចម៏គោនោះដុតជាផង
ហើយលាបថ្ងាស លាបមុខទុកជាស្រីសួស្តីមង្គល ។ ចុះពួកខ្មែរ
យើងនេះកាន់សំពះសាសនាព្រះសម្មាសម្ពុទ្ធ តីគោតមបរមគ្រូ
ទេ ហេតុម្តេចក៏ទៅសំពះបូជាគោ តាំងនាមជាព្រះគោ ហើយ
មានសេចក្តីសៅសោកអាល័យដល់ព្រះគោ ដែលនគរសៀមគេ
យកទៅនោះ ខ្មែរយើងនឹងបានទៅកាន់ព្រះគោជាយានរបស់
ព្រះឥសូរ ដូចពួកឥណ្ឌូនោះកាលណា ក៏នឹងទៅអាល័យព្រះគោ
នោះឬ កាន់ថាគោសព្វនេះ ជានាមព្រះគោតម ព្រោះព្រះពុទ្ធ
ជាម្ចាស់យើងជាទង្វគោតមគោត្រត្រូវគ្នានឹងគោសត្វបានជា
ទាប់អានគោរពគោ ទើបតាំងសិតសាងជារូបគោ តាំងជាទីបូជា
របស់ខ្មែរដែលកាន់ព្រះពុទ្ធសាសនាអើបើដូច្នោះ សត្វគោក្នុង
ស្រុកខ្មែរនេះក៏មានទួទៅហេតុម្តេចខ្មែរក៏នៅនាំគ្នាប្រើគោ
ជាពាហន: ជាយានបរទេះភ្ជួរស្រែ ហើយព្រមទាំងសម្លាប់ស៊ី
សាច់ផងហេតុម្តេចក៏មិននាំគ្នាសំពះបូជាគោសព្វថ្ងៃនេះទៅផង

គោជាគោដូចគ្នា ។

ន័យមួយទៀតទៀត មានពួកខ្លះជ្រើសំពះរូបយាយទែព បន់
ស្រន់យាយទែព ដោយក្តីប្រាថ្នា អ្នកកាន់សំពះយាយទែពនេះ ក៏
ពុំដឹងដើមហេតុទ្បើងប្រទំត្តីនៃយាយទែពនោះជាអ្វី រូបយាយ
ទែពនោះកាលរស់នៅ តើគាត់ជាទេវតា ឬ ជាមនុស្សយើង
នេះគាត់ជាប្រពន្ធតាណា តានោះឈ្មោះអ្វី កាលរស់នៅ តើមាន
បុណ្យបារមីអាចជួយដោះទុក្ខខ្មែរយ៉ាងណាខ្លះឬ បានជួយប្រាប់
សត្រូវខ្មែរយ៉ាងណាខ្លះ ជួយការពារសព្វទោគយ៉ាងណាខ្លះ មាន
គុណនឹងផែនដីយើងនេះដូចម្តេចខ្លះ, តម្រាទ្បើងប្រទំត្តីយាយទែ
ពនោះ តើមាននៅក្នុងតម្រាពង្សាវតារឬក្នុងគម្ពីរសាស្ត្រាបាលី
ឯណាបានជាពួកនេះទៅជ្រើទៅបូជាអួតថាពូកែនោះ ។ អើ
បើដូចជារូបនាងសាន្តាវ៉ូ មានក្នុងពង្សាវតារបាទាំងសែស នោះ
ទើបគួរដល់លោកអញ្ញូនកជាតិបាទាំងសែសគេគោរពបូជា
ព្រោះនាងកាលរស់នៅនោះ បានជួយអាសាមហាក្សត្រ ចេញ
ជានាយទាហានលើកពលយោធាច្បាំងនឹងពួកបច្ចាមិត្រ ទាយយក
ខេត្តដែនរបស់ជាតិខ្លួនបានមកទិញ ដល់ក្រោយនាងអស់បុណ្យ
ដោយដៃពួកបច្ចាមិត្រចាប់ទៅដុតភ្លើងទាំងរស់ពួកអ្នកនគរ..

គេនឹកដល់គុណនាង ដែលជួយយកអាសាផែនដីនោះ ទើបគេនាំគ្នាសិតសាងរូបនាងទុក គឺជាស្រីអស្ចារ្យតម្កល់ឲ្យពួកជាតិដូចគ្នាគោរពបូជារបស់គេ ត្រាលុះដល់មកសម័យឥឡូវនេះ ។

ឯយាយទែពនោះ តែកាលគាត់រស់នៅ បានជួយដោះទុក្ខជាតិខ្មែរយើងយ៉ាងណា ទើបបានបុរាណចាស់គេសាងរូបយាយទែពនេះទុក ឲ្យពួកខ្មែរយើងគោរពបូជារូបគាត់ ត្រាដល់មកឥឡូវនេះ ។

មួយទៀត ពាក្យទែពសព្ទនេះ ជាភាសាក្លាយមកពីភាសាសំស្ក្រឹតថា "ទែត្យ" ប្រែថាខ្មោចយក្ស. អើទៀងខ្មោចយក្សនោះ សឹងជាសត្រូវនឹងជាតិមនុស្សយើងនេះទេ ហេតុម្តេចក៏គេទៅបូជាទាំនោះទៀត ឬពាក្យទែពសព្ទនោះ ពុំមែនជាទែពនោះទេ គឺថាសព្ទទែពហៅថានាងទែពធីតា សំដៅយកនូបនាងឱមាភគវតី ជាអគ្គមហេសីនៃព្រះឥសូរនោះទេដឹង? ព្រោះមនុស្សជាន់ដើមកាន់សាសនាព្រះឥសូរាធិបតី នាប់អាននាងឱមាភគវតី ព្រោះនាងជាមហេសីនៃព្រះឥសូរនោះទើបគេសិតសាងរូបនាងតាំងទុកមក ហៅថា យាយទែព ។ នោះដល់យូរមកយានពាក្យហៅថាយាយទែព យ៉ាងនេះទេដឹង? អើបើទុកជារូប

នាងឱមាភគតីក្តី យើងជាឱបាសកឱបាសិកានាប់អានព្រះពុទ្ធសាសនានេះមិនត្រូវទៅគោរពសំពះបូជារូបយាយទែពនោះទេ ធ្វើឲ្យសៅហ្មងខាតបង់ត្រៃសរណគមនីរបស់ខ្លួនសោះទទេយ៉ាងនេះ ។

មួយទៀត មានអ្នកខ្លះទៅជឿពាក្យព្រេងនិយាយកុហកកូនក្មេងតមកថា ភ្នំក្រោមនៅខេត្តស្រុកសៀមនាប ១ ភ្នំត្រដិលនៅខេត្តស្រុកដើងព្រៃ ១ ភ្នំទាំង ២ នេះ ពុំមានដើមឈើដុះលើច្រូងច្រាងដូចយ៉ាងភ្នំឯទៀតៗ គឺភ្នំនេះកាលព្រះនាមចងថ្កល់លើកពលពួកពានរ ទៅយុទ្ធនាឯក្រុងនាពណាសូរនៅកោះលង្កា បានប្រើឲ្យកំហែងហនុមានជញ្ជូនថ្មភ្នំចងថ្កល់ ។ ហនុមានមានទឹទ្ធំខ្លាំងចងភ្នំតូចធំនឹងសរសៃនាមហើយហោះមកឯភ្នំពីរនេះដាច់ចាកនាមហនុមានធ្លាក់សំយុងចុះក្រោមបាតទៀងលើ ទើបឈើមិនដុះបាន កូនក្មេងឥតសតិបញ្ញាជឿតាម ប្រកាន់មាំថាមែន ដល់ខ្លួនចាស់ក៏នៅតែជឿ ព្រោះពុំមានសតិសម្បជញ្ញៈនឹងពិចារណាមើលហេតុមើលបច្ច័យ ធម្មតាលោកទៀយ ដូចនិទានទៀងតាហូឡាន មានកូនប្រសា ២ នាក់ ។ ចៅបងជាមនុស្សឥតសតិបញ្ញាឮតែពាក្យអាពុកក្មេកថាដូចម្តេច ក៏ធ្វើតាម ឯតាហូឡានក៏..

ស្រទ្បាញ់នាប់អានចៅបងនោះ។ ឯចៅប្អូនពុំគាប់ចិត្តអាពុកក្មេកព្រោះជាអ្នកមានសតិបញ្ញា មិនផ្ទុំមិនប្របតាមការខុសការមិនគួរដឿ។

ថ្ងៃមួយតាហូទ្បាន នាំចៅកូនប្រសាទាំង២ចុះទូកចែវទៅព្រៃដើមឫទៅកាប់ឈើ លុះចែវទៅដល់ទីទាល១ ឮសម្លេងក្រៀលទាយំកងឡើង អាពុកក្មេកក៏សួរទៅកូនប្រសាថា អើដឹ សត្វក្រៀលសត្វត្រយងនោះ ម្តេចក៏ទាយំសម្លេងឮខ្លាំងម្ល៉ះ?។

កូនស្រាបងឆ្លើយថា បាទ! បានជាទាមានសម្លេងនោះ ព្រោះកទាទែង ទើបបានជាមានសម្លេងឮ ឯចៅកូនប្រសាប្អូនចែវកន្ទែ្របានឮពាក្យអ្នកទាំង២ និយាយត្រូវគ្នាដូច្នោះ ក៏ទាស់ចិត្តណាស់ ទើបឆ្លើយទៀងថា សត្វហ៊ុងកូនក្អាត់នោះ តើកទាទែងកាលនា ម្តេចទាមានសម្លេងឮដែរ។

ឯចៅអាពុកក្មេកនិងកូនប្រសាបង ក៏ទាស់បញ្ញាពុំអាចឆ្លើយតប ទើបនាំគ្នាស្ទៀមនៅ លុះចែវទៅដល់ទីគោកទួល១ ទួលនោះទល់ងពុំមានស្មៅដុះទើបអាពុកក្មេកសួរទៀតថា អើទីទួលនេះម្តេចពុំមានស្មៅដុះ? ឯចៅកូនប្រសាបងឆ្លើយថា កាលដើមតាព្រហ្មគាត់មកដាំបាយ ហើយគាត់ជាត់ទឹកបាយទៅលើទួលនេះ

ហេតុនេះទើបស្មៅដុះពុំបាន ព្រោះទឹកក្តៅត្រូវទស្មៅស្លាប់អស់។

ចៅអាពុកក្មេកក៏ទទួលថា អើមែនទឹកបាយតាព្រហ្មគាត់ជាត់ដាក់ទៅលើទីនេះ ស្មៅឯងដុះឯណាបាន។

ឯចៅកូនប្រសាប្អូនក៏ឆ្លើយកាត់ទៀងថា មនុស្សក្បាលតំពែកសក់ទាមិនដុះនោះ តើតាព្រហ្មគាត់ជាត់ទឹកបាយដាក់លើដែនឬម្តេច? អ្នកទាំង២ ក៏ទាស់ស្ទៀមនៅ។ លុះចែវទៅដល់ទីជ្រុងភ្នំបានឃើញថ្មបែកប្រេះ អាពុកក្មេកក៏សួរថា អើហេតុអ្វីថ្មនេះក៏បែកដូច្នេះ ចៅកូនប្រសាបងឆ្លើយថា កាលព្រះនាមព្រះលក្ខ្មណ៍លោកអូសព្រះខ័នមកត្រង់នេះ ថ្មនេះត្រូវនឹងចុងព្រះខ័ន ទើបទាបែកយ៉ាងនេះ។ ឯពុកក្មេកក៏តបថា អើព្រះខ័នព្រះនាមមុតណាស់ តែលោកអូសទៅត្រូវនឹងអ្វីៗ ហើយគង់បែកគង់ដាច់មិនខាន។

ចៅកូនប្រសាប្អូនក៏ឆ្លើយកាត់ទៀងថា ចង្វែកក៏តមនុស្សយើងនោះ តើព្រះនាមអូសព្រះខ័នដែរឬ? បានជាទាបែកយ៉ាងនេះ?

ឯអ្នកទាំង២ ក៏ទាស់បញ្ញា មិនអាចហើបហាថាអ្វីតទៅទៀតទៀយ ទើបចែវទៅដល់ព្រៃឈើនាំគ្នាកាប់បានក៏វិលមកផ្ទះវិញ។

ឯងស្តាប់មើលចុះ មនុស្សយើងនេះ សឹងឥតសតិបញ្ញានឹងពិចារណាឲ្យឃើញធម្មតាលោកិយ ទៅជឿតែសំដីព្រៃឯនិយាយបញ្ឆោតកូនក្មេងលេងតៗ មកដូចតាហូទ្បាន ចាញ់សំដីចៅកូនប្រសាប្អូនដូចពណ៌នាមកនេះ។

មួយទៀត ជាតិមនុស្សប្រុងយើង ទោះជាខ្លៅល្ងង់ឆោតយ៉ាងណាៗ ក៏ពុំទទួលខ្លួនថាឆោត ថាពុំចេះនោះទេ្បីយ សឹងអួតថាខ្លួនចេះដឹង ថាខ្លួនមិនឆោតទាំងអស់។

ដូចនិទានចៅឆោតម្នាក់ដឹះក្របីទៅស្រែ យកស្រូវ១ល្អីទៅសាបផង ចៅនោះគិតថា អញ្ជើះក្របីនេះទាធ្ងន់ទាហើយ បើឯងដាក់ស្រូវ១ល្អីនេះលើខ្នងទាទៀត ទាទឹតតែធ្ងន់គ្នាណាស់ គួរតែជួយទូលទាកុំឲ្យគ្នាធ្ងន់ពេក ចៅនោះគិតដូច្នោះហើយ ទើបដឹះក្របីទូលស្រូវទៅបរទៅកាន់ស្រែនៃអាត្មា។

កាលណោះ មានមហាក្សត្រាធិបតី ប្រើរាជអមាត្យ ឲ្យដើរទកមើលមនុស្សឆោត ក្នុងព្រះនគរក្រៅព្រះនគរ ថាបើមានមនុស្សឆោតនៅក្នុងទីណានោះ ឲ្យអមាត្យនាំមនុស្សនោះចូលទៅគាល់នឹងព្រះរាជទានរង្វាន់ឲ្យរាជអមាត្យតាមក្តីគាប់។ ឯអមាត្យក៏ដើរត្រាច់មើលមនុស្សទាំងឡាយ តាមតំបន់ពុំមាន

ឃើញមានមនុស្សឆោត១ទេ្បីយ, លុះដើរមកដល់ទាលស្រែបែរទៅឃើញចៅដឹះក្របី ទូលល្អីស្រូវដូច្នោះ ក៏សំគាល់ថាចៅនោះឆោតពិតប្រាកដទើបសួរទៅថា ចៅឯងនេះ ដឹះលើខ្នងក្របីហើយស្រូវ១ល្អីនោះ ម្តេចមិនដាក់លើខ្នងក្របីទៅ ម្តេចចាំទូលផង ចៅឯងម្តេចឆោតម្ល៉ះ ចៅឯងឆោតឬឆ្កួតយ៉ាងណា? ឯចៅនោះ ពុំទទួលខ្លួនជាឆោតល្ងង់ទើបតបទៅថា ខ្ញុំបាទនឹងឆោតល្ងង់កាលណា គឺខ្ញុំបាទចេះ ចេះគិតឃើងថាខ្លួនដឹះលើខ្នងគ្នាៗធ្ងន់មួយសាហើយ សមដាក់ស្រូវ១ ល្អីថែមលើខ្នងគ្នាទៀតក្តីធ្ងន់គ្នាក៏ទឹតទ្វេទ្បើងៗ ហេតុនោះ ខ្ញុំបាទមេត្តាក្របីខ្ញុំបាទ ទើបជួយទូលទាយ៉ាងនេះ ហេតុដូចម្តេចក៏លោកមកពោលថា ខ្ញុំបាទឆោតល្ងង់នោះ។

ឯរាជអមាត្យនិយាយពន្យល់ទៀត ចៅនេះ ក៏មិនទទួលតាម ថាខ្លួនឆោតទេ្បីយ រាជអមាត្យអស់ប្រាជ្ញា ទើបគិតថា មែនហើយមនុស្សយើងនេះប្រតិបត្តិការខុស ឆោតល្ងង់ ជាប់ទូវត្តិប្រកាន់ខ្ជាប់ហើយ ទោះគេនិយាយពន្យល់យ៉ាងណាៗ ក៏តាម នៅទឹងទទឹងដោយទឹដ្ឋខ្លាំងៗ រាជអមាត្យដើរទកមនុស្សឆោតល្ងង់ទទួលខ្លួនជាឆោតល្ងង់ពុំបានទេ្បីយ ហើយក៏ចូលទៅព្រះនគរ

ក្រាបទូលស្តេចដោយសេចក្តីរកពុំបានមនុស្សទទួលខ្លួនឆោតល្ងង់ដូចពណ៌នាមកនេះ ។

មានទើងតម្រាឃ្លានស្រទ្បាញ់ចុះឆោត ដូចសត្វសិង្ហតោ១ បានឃើញកូនក្រមុំចៅនាយដង្កៅម្នាក់ក៏កើតចិត្តស្រទ្បាញ់ចង់បានជាភរិយា ទើបចូលទៅនិយាយនឹងដង្កៅ ជាមាតាបិតានៃនាងថា ខ្ញុំស្រទ្បាញ់កូនក្រមុំលោក សូមលោកមេត្តាដល់ខ្ញុំឯទើងតែងអាពាមង្គលនោះ សូមឲ្យលោកបង្គាប់មកចុះ ខ្ញុំនឹងទៀបមកជូនឲ្យពេញចិត្ត កុំឲ្យលោកកោតញ្ញើតទៀយ ។

ឯដង្កៅនោះ ឮសិង្ហតោ មកពោលពាក្យចង់បានកូនខ្លួនជាប្រពន្ធដូច្នោះ ក៏គិតថា អាសិង្ហតោនេះជាជាតិថយថោក មិនគួរនឹងលើកកូនក្រមុំឲ្យជាភរិយាឲ្យខូចទៅកូនអញ្ញ បើនឹងមិនឲ្យទៀ ជាសត្វអង់អាចកាចឃោរឃៅ ទាំអាងចង្កូមនឹងក្រចកជើងវាជាអាវុធវានឹងយាយីឯង ឲ្យដល់នូវក្តីវិនាសទៅផ្សេងៗ បើដូច្នេះ មានតែនិយាយលួង កាត់អាវុធវាចេញទើបកែខ្លួនសុខបាន គិតហើយ នាយដង្កៅនិយាយទៅថា អើសិង្ហតោ អ្នកឯងមកចង់បានកូនយើងជាភរិយានេះ យើងក៏គាប់ចិត្តណាស់ចង់បានបាឯងជាកូនជាចៅពិតៗ ព្រោះយើងឥតឫទ្ធិអំណាចនឹងទកក្នាទៀងទ្រត្រកូលឲ្យមាំមួនតទៅ តែខាងចិត្តកូនស្រីយើងនេះជាទាស្មើគ្រព្រាក់ព្រមស្រទ្បាញ់បាឯង ឬយ៉ាងម្តេចនោះ យើងពុំបានទាន់ដឹង បើដូច្នោះ ចូរបាឯងនៅនេះសិនចុះ ចាំយើងចូលទៅនិយាយនឹងទាមើលសិន ថាហើយទើបចូលទៅក្នុងផ្ទះបន្តិច ក៏ចេញមកវិញ ហើយនិយាយថា យើងបាននិយាយនឹងកូនយើងស្រេចហើយ ទាព្រមស្មើគ្រនឹងអ្នកឯងដែរតែទាថា អ្នកឯងមានក្រចកទៀងស្រួចណាស់ ក្រែងបានគ្នាទៅ អ្នកឯងលូកប្រទ្បែងលេង បិចថ្ពាល់ បិចដោះក្តី ទាខ្លាចក្រែងមុតថ្ពាល់ មុតដោះ, មួយទៀ ក្រែងអ្នកឯងថើបឱបជញ្ជបថ្ពាល់ឬ មុខមាត់ទៅ ប៉ះត្រូវចង្កូមនឹងមុត ហេតុនេះ បើអ្នកឯងឲ្យយើងកាត់ចង្កូម កាត់ក្រចកចេញខ្លះនោះ ទើបកូនយើងទាព្រម ។

ឯសិង្ហតោ លុះអំណោចក្តីឃ្លានស្រទ្បាញ់គ្របសង្កត់ ក៏ឆោតទើបថា អញ្ជើញលោកនកគេមកកាត់ក្រចកកាត់ចង្កូមខ្ញុំចុះ ថាហើយ ក៏ដេកហាមាត់លាត់ក្រចកឲ្យនាយដង្កៅកាត់, នាយដង្កៅក៏ហៅកូនក្មួយជួយគ្នាកាត់ត្រើងអាវុធនៃសិង្ហតោនោះ ។ ឯសិង្ហតោនោះ ក៏លុះត្រូវគេកាត់ក្រចកដកចង្កូមអស់ហើយក៏សើ្យយកម្លាំង សើ្យយឫទ្ធិចុះ, ឯនាយដង្កៅនោះដឹងថា សិង្ហតោអស់ឫទ្ធិ

ហើយ ក៏ហៅពួកកូនក្មួយជួយគ្នាដេញវាយសិង្ហតោ, អ្នកខ្លះបានដំបង ខ្លះបានដាវលំពែង តាំងដេញចាក់ ដេញប្រហារសិង្ហតោ ៗអស់ប្ញទ្ធីនឹងតស៊ូ ក៏រត់ចូលព្រៃទៅ បានស្តេចក្តីវេទនាផ្សេង ៗហោង ។

ទៀងនេះ ឯងស្តាប់មើលចុះ ហើយប្រៀបដោយមនុស្ស យើងសព្វថ្ងៃនេះ មានលោកចៅអធិការ ឬលោកអ្នកឯណោ ៗ មានសម្បត្តិ ត្រូវទៅមេស្រីអ្នកលេងទាបញ្ឆោតដោយកលតាមវាគ ថាទាំដោយហើយ លើកសម្បត្តិឲ្យទៅទាំមុនអស់ ដល់ខ្លួនសឹក ទៅ ទាំគេចជាមិនស្នេហាវិញ នឹងទាំរយកទ្រព្យសម្បត្តិវិញ ទាំគេចកែប្រែជាពុំបានទទួល មិនបានដឹងឮទ្រព្យនោះ នឹងយកវិញពុំបាន ដូចយ៉ាងសត្វសិង្ហតោ ឲ្យគេកាត់ក្រចកដកចង្កូមអស់ គួរគិតមើលទៅទៀតចុះ តាមទៀងឃ្លានស្រឡាញ់ឆោតនេះ ឯង ។

និទានក្នុងទសជាតកថា កាលមហោសថបណ្ឌិត រត់ចូលនាងអមរាទេវី ភៀសអាត្មាជាមនុស្សសាមញ្ញ ទៅនៅអាស្រ័យនឹងពួកស្មូនឆ្នាំងនោះក្រោយនោះ អាចារ្យទាំង៤នាក់ គឺអាចារ្យសេនក១ អាចារ្យបុក្កុល១ អាចារ្យកាមិន្ទ១ អាចារ្យទេវិន្ទ១ អាចារ្យ

ទាំង៤ នោះដឹងថា ព្រះមហោសថបណ្ឌិតរត់ចេញចាកលំនៅ ដោយកលឧបាយរបស់ខ្លួនដែលទូលញុះញង់ ឲ្យព្រះបាទវិទេហរាជកើតស្អប់ចៅមហោសថនោះ សមក្តីប្រាថ្នាខ្លួនហើយ ក៏មានចិត្តត្រេកអរនឹក្រៃពេក កើតចិត្តប្រមាថនាងអមរាទេវីជាភរិយានៃពោធិសត្វ ចង់បាននាងជាភរិយាទីទៃ ៗ, តែកាលអាចារ្យទាំង៤ គិតទៅចង់នាងអមរានោះ សឹងគិតគំនិតទៀងខ្លួន នឹងបានដឹងគ្នាក៏ទេ ។

ថ្ងៃមួយ, អាចារ្យទាំង៤ ប្រើមេអណ្តើកឲ្យនាំយកមាស់ប្រាក់ទៅជូននាង ហើយនិយាយផ្ញើទៅលោកិយផ្ទាន់ស្រីមេម៉ាយប្តីបង់ចោល ។

ឯនាងអមរា កាលនាបើដឹងថា អាចារ្យទាំង៤ ចង់បាននាង ដូច្នោះហើយក៏និយាយប្រាប់មេអណ្តើកទាំង៤ នាក់នោះថា ខ្លួននាងជាស្រីមេម៉ាយប្តីរត់ចោល នៅកន្លែងឯកាឥតទីពឹង ឥឡូវនេះ បើលោកអាចារ្យមេត្តាប្រោសនាង ឲ្យបានទីពឹងនោះនាងក៏សែនត្រេកអរ នឹងគុណលោកអាចារ្យណាស់ហើយនាងក៏ព្រមតាមអធ្យាស្រ័យ តែឯងទៅប្រាប់នាយឯងទីទៃ ៗថា បើលោកចង់មកផ្ទះនាងនោះ ឲ្យអញ្ជើញមកនៅលាយប់ស្អែកនេះ ថាហើយ

ទើបសនសេនជាសំបុត្រកំណត់សញ្ញាពេលឲ្យមក ស្រេចហើយ
ប្រគល់ឲ្យមកមេអណ្តើកទាំង៤ ឲ្យនាំទៅឲ្យនាយនៃខ្លួនទីទៃ។
ក្រោយនោះ នាងអមនាចាត់ប្រើទាសាទាសី ឲ្យដឹកនណ្តៅ១
ដង្រៀលិចក្បាលហើយឲ្យយកលាមកចាក់ទឹកឲ្យនលាយចំនួនត្រឹម
មចង្កាមាត់ ហើយឲ្យធ្វើជាយន្តគន្លឹះ បិទបាំងតាំងនូវពាងទឹក ហើ
យទាសាទាសីចាំនៅនកង្រា នាងឲ្យសញ្ញាដល់ទាសីទាំងឡាយ
តាមឱបាយនាងគិតនោះឯង។

ឯអាចារ្យសេនក លុះបានទទួលសំបុត្រនាងបានអានមើលដឹង
សេចក្តីហើយ ក៏ត្រេកអរនឹក្រែពេកលុះដល់ទាត្រីម៉ោង៨ អាចារ្យ
ក៏ទៀបចាត់ចែងតែងកាយ ស្លៀកពាក់សមគួនហើយ ក៏ចេញចា
កគ្រឹះស្ថាន ដើរឆ្ពោះទៅកាន់ផ្ទះនាងអមនា ដល់ហើយក៏ឈរនៅ
មាត់ទ្វារ គោះទ្វារជាសញ្ញា។

ឯពួកទាសីទាសានាងអមនា បានឃើញអាចារ្យសេនកមកដល់
ក៏នាំគ្នាចេញទៅទទួល ហើយនាំចូលទៅក្នុងបន្ទប់ទឹក ន័យាយ
ប្រលោម ថា "លោកនាយ, ខ្ញុំម្ចាស់ផ្តាំថា បើលោកតាមកដល់សូម
ឲ្យលោកតាងូតទឹកជម្រះសរីរកាយ បំព្រំប្រោះទឹកអប់សិន សូម
អញ្ជើញទៅតំណាក់ព្រះនាង"។

ឯអាចារ្យសេនក ត្រូវនមេទាសីនាប្រលោម ក៏ព្រមផ្តាស់សំព
ត់ដោះអានិ ចិញ្ជៀនពេជ្រឲ្យនមេទាសីនាកាន់ឲ្យ មេខ្លះនាំចូល
ទៅក្នុងល្វែងបន្ទប់ ឲ្យអង្គុយលើក្តារយន្ត មេខ្លះយកផ្តិលប្រាក់
ដងទឹកស្រោច មេខ្លះធ្វើជាជួយដុសកែលឲ្យ លុះងូតបន្តិចមេ
អស់នោះទាញយន្តទៀង ឯក្តារនោះក៏ភ្លាត់ចាកទីបះទៀង,
អាចារ្យសេនក ក៏ធ្លាក់ចុះទៅក្នុងនណ្តៅអាចម៌នោះ ដើបតែត
ទៀងឲ្យផ្ទុតអំពីលាមកនៅនងទុក្ខដូចសត្វនៅគូថនរក
នោះឯង។

ថ្លែងឯអាចារ្យបុក្កុសនោះ លុះដល់យប់ម៉ោង៩ ក៏ចាត់ចែង
តែងខ្លួនទៅផ្ទះនាងអមនា, ឯពួកមេទាសីនាក៏ប្រលោម ដូចបទ
អាចារ្យសេនកហើយ នាទាញយន្តទម្លាក់អាចារ្យបុក្កុសនោះ
ទៅក្នុងនណ្តៅគូថជាមួយនឹងអាចារ្យសេនកនោះឯង។

លុះដល់ពេលម៉ោង១០ អាចារ្យទេវិន្ទទៅចុះកលដូចអាចារ្យ
ទាំងអស់, អាចារ្យទាំង៤ នៅក្នុងនណ្តៅគូថនងទុក្ខនេទនាដោយ
លាមកជោនពោនទៀងដល់ត្រឹមចង្កាមាត់ បាននឹងគ្នាថាចុះកល
នាងអមនាទេវីនៅនងទុក្ខអស់១នាត្រី លុះព្រឹកទៀងនាងអមនា
ប្រើពួកទាសីទាសា យកនងកទាក់កអាចារ្យទាំង៤ ទាញទៀង

ចាកនណ្តៅ ហើយឲ្យយកទឹកចាក់លាងសព្វសាវពាង្គកាយនៃអាចារ្យ ឲ្យយកដុំតង្កុដុំសក្បាលអាចារ្យទាំង៤។

ឯអាចារ្យទាំង៤ បានសេចក្តីឈឺចាប់ដោយមេទាសីនាំទួសកោសដុំសដោយដុំតង្កុនោះឯង លុះជម្រះលាងកាយអាចារ្យភ្ជាប់គ្នាហើយឲ្យអ្នកបម្រើសែងអាចារ្យដូចគេសែងខ្មោច, នាងក៏ចូលទៅក្នុងព្រះរាជវាំងនាំយកអាចារ្យទាំងនោះ ទៅថ្វាយដល់ព្រះបាទទីទេហរាជ, ស្តេចឲ្យស្រាយសំណុំកន្ទេលមើល ស្រាប់តែឃើញអាចារ្យទាំង៤ នៅក្នុងនោះទើបទ្រង់ត្រាស់សួរនាងអមរាៗក៏ក្រាបទូលតាមដំណើរអាចារ្យទៅកំហែងប្រមាថនាង តាំងអំពីដើមដល់ចប់សព្វប្រការ។

ព្រះបរមរាជាបានទ្រង់ស្តាប់ដូច្នោះក៏ទ្រង់ព្រះពិរោធខ្លាំងនឹងអាចារ្យទាំង៤ហើយទ្រង់ត្មះតិះដៀលដោយពាក្យអាក្រក់ផ្សេងៗ ទ្រង់បណ្តេញឲ្យទៅផ្ទះទៀងខ្លួនទីទៃ។

ឯអាចារ្យទាំង៤បានសេចក្តីអប្បយសខ្មាសអស់បណ្តាមហាជនទាំងឡាយពុំអាចនឹងទៅកានទីជំនុំប្រជុំជនានុជនផងបាន ខានចូលព្រះរាជវាំងអំពីថ្ងៃនោះមក។

ឯនាងអមរាទេវីលុះសម្រេចកិច្ចខ្លួនហើយក៏ក្រាបថ្វាយបង្គំលាស្តេចនាំពួកបរិវារនាងវិលទៅកាន់គ្រឹះស្ថាននាងវិញហោង។

រឿងនិទាននេះមានសេចក្តីពិស្តារក្នុងគម្ពីរទសជាតកឯណោះ មានសេចក្តីតទៅទៀតយើងទាញយកតែបទត្រង់នេះមកសម្តែង ដើម្បីឃើញសេចក្តីត្រង់តម្រាឆោត កើតដោយសេចក្តីឃ្លានស្រទ្បាញ់នេះឯង។

ចប់តម្រាឃ្លានស្រទ្បាញ់ឆោត

អាចារ្យបាំងឈើ ភ្លើៗទៅលើ នួននាងអមរា ជាកល្យាណីស្ត្រីមានបញ្ញា បំពោតឲ្យអាចារ្យធ្លាក់នណ្តៅ ទោសគឺក្តីស្នេហ៍ឆោលុះទាល់តែ បង់ប្រាណបានន្ទូវ ក្តីធ្លាក់ថ្លស់យស ខុសនឹងព្រះចៅតម្រានេះហៅ ឆោតឆៅព្រោះស្ត្រី។

តម្រាឃ្លានអាហារឆោត

មានសត្វក្រពើ១នៅក្នុងបឹងធំលុះដល់រដូវប្រាំងទឹកបឹងនោះក៏រីងខះអស់ក្រពើនោះនៅពុំបានទើបវាទៅរឹងគោកដើរត្រាច់រកទីមានទឹកនឹងអាស្រ័យ។

ឯក្រពើក៏សូមដោយសារទេះតានោះ តានោះសួរថា "ចៅឯងតើនឹងទៅឯណា? ក្រពើប្រាប់ថា "ខ្ញុំបាទនេះរកទីអាស្រ័យពុំបានគឺបឹងដែលខ្ញុំបាទធ្លាប់នៅនោះ ឥឡូវទឹកវិងខះអស់នឹង

នៅតទៅពុំបាននឹងទៅស្វែងរកបឹងឬស្ទឹងទន្លេឯណា ដែលមានទឹកនោះនឹងអាស្រ័យនៅ ថាបើតាមេត្តានាំខ្ញុំបាទទៅបានដល់ទីត្រង់ណាដែលមានទឹកនោះ សូមតាមេត្តាដាក់ខ្ញុំបាទត្រង់ទីនោះចុះ"។

ឯតានោះក៏ព្រម ទើបដោះគោចេញចាកនឹមហើយឲ្យក្រពើទៀងជិះលើទូកនទេះ ឯក្រពើនោះខ្លួនទៀងក៏លូនក្រាបក្បាលដល់ក្បាលក្រពើនទេះហើយមិនទុកចិត្តខ្លួនក្រែងធ្លាក់ ទើបឲ្យតានោះយកខ្សែមកចងខ្លួនភ្ជាប់នឹងទូកនទេះ តានោះក៏ធ្វើតាមពាក្យក្រពើស្រេចហើយ តាក៏ទឹមគោបនចេញអំពីទីព្រៃនោះ លុះត្រាដល់ទីបឹងមានទឹក១, តានោះក៏បញ្ឈប់នទេះដោះគោចេញ ហើយស្រាយចំណងក្រពើប្រាប់ថា "បឹងនេះគួនហើយចូរអ្នកឯងលូនទៅនៅបឹងនេះចុះ"។

ឯក្រពើជាសត្វអកតញ្ញូមនដឹងគុណគេមានសេចក្តីឃ្លានអាហារដោយអត់មកយូរថ្ងៃហើយក៏និយាយទៅថា "តាឯងនេះចងយើងភ្ជាប់ទូកនទេះយើងបានសេចក្តីទុក្ខវេទនាពន់ពេកណាស់តាឯងត្រូវឲ្យគោយើង១ស៊ីទើបតាឯងនួចទោសថាបើមិនឲ្យគោដល់យើងទេ ត្រូវឲ្យយើងស៊ីតាឯងក្នុងកាលឥឡូវនេះ"។

ឯតានោះលុះឮក្រពើពោលពាក្យដូច្នោះ ក៏ភិតភ័យទើបស្តីអង្វរថាអ្នកក្រពើខ្ញុំឯងនេះមានគុណបានដឹកនាំបាឯងមកដល់ទីនេះ ឥឡូវបានឯងសុំខ្ញុំវិញការនេះ ខ្ញុំឯងឥតទោសសោះមិនគួរនឹងពិឃាតបើដូច្នេះ ខ្ញុំពុំសុខចិត្តចាំខ្ញុំទៅនកលោកចៅក្រមឲ្យលោកវិនិច្ឆ័យទៀងក្តីនេះសិន សឹមប្រតិបត្តិទៅមក, ឯក្រពើក៏ព្រមថា "អើ តាឯងទៅនកចៅក្រមណាក៏ទៅឲ្យឆាប់ចុះយើងពុំខ្លាចទេ"។

ឯតានោះបានចេកទុំ១ស្លឹត ក៏កាន់ដើរទៅនកចៅក្រម, កាលនោះមានសន្ធាយគល់១ នៅលើទួលដំបូកបានឃើញតាកាន់ចេកដើរកាត់ព្រៃចូលមក ទន្ធាយក៏សួរទៅថា "តាអើយតាៗឯងមាននេត្រាផលជោរសោកសៅ ដោយមានទោសទុក្ខយ៉ាងណា? មកនេះតើនឹងទៅស្លាន់ឯណា?"។

ឯតានោះក៏និយាយសេចក្តីខ្លួននឹងក្រពើតើតហេតុនឹងគ្នាប្រាប់ទន្ធាយនោះសព្វប្រការ"។

ទន្ធាយបានស្តាប់ដូច្នោះក៏ថាអើអាសត្វក្រពើនោះ ជាសត្វមិនដឹងគុណតាឯង បើដូច្នោះខ្ញុំនឹងទទួលទៅជាចៅក្រមជម្រះឲ្យតាឯងកុំភ័យទៀយឲ្យតែចេកនោះមកខ្ញុំស៊ីសិន សឹមទៅជាមួយ

គ្នា ។ តានោះក៏ឲ្យចេក១ ស្ងិតទៅសុភាទន្ទ្រាយ។បទិភោគចេកនោះអស់ហើយ ក៏នាំគ្នាទៅទីតំណាក់ដែលឈប់នោះ ដល់ហើយសុភាទន្ទ្រាយនិយាយទៅថា "ម្តេចចៅក្រពើចៅឯងនៅឆ្ងៃឆ្ងល់ទៅព្រៃមិនដឹងជាទៅណាបានតាគាត់មេត្តាឲ្យដោយសារមកផងឥឡូវបានដល់ទីសមគួរ និងរកអាស្រ័យនៅហើយម្តេចចៅគិតទៅរកឃ្លើគុណគេ គិតនឹងសុំគេវិញគេធ្វើទុក្ខទោសអ្វីឲ្យដល់ចៅឯង" ។

ឯក្រពើក៏ឆ្លើយថា "អើលោកសុភាតានេះគាត់ឲ្យខ្ញុំដោយសារមកនេះក៏មែនប៉ុន្តែគាត់ធ្វើបាបខ្ញុំខ្លាំងណាស់គឺគាត់ចង់ខ្ញុំភ្ជាប់ទៅនឹងទូកនេះខ្លាំងពេក រកតែនឹងទៅខ្លួនដកដង្ហើមក៏ពុំបានគាត់ធ្វើទុក្ខខ្ញុំយ៉ាងនេះបានជាខ្ញុំខឹង ត្រូវឲ្យគាត់ប្រគល់គោគាត់បាន១ ឲ្យខ្ញុំស៊ី ថាបើគាត់ពុំព្រមឲ្យគោនោះទេត្រូវស៊ីគាត់វិញ" ។

ទន្ទ្រាយក៏ឆ្លើយអនុលោមតាមថា "អើតាៗឯងចងគេតឹងខ្លាំងហួសបានជាគេខឹង ចុះតាឯងម្តេចក៏ចងគ្នាតឹងម្លេះ គ្មានកន្លែងទៅខ្លួនមិនរួចដូច្នោះតា?" ។

តានោះថា "ទេ, ខ្ញុំបាទចងធូរទេលោកចងល្មមតែជាប់ពុំឲ្យ

ធ្លាក់ប៉ុណ្ណោះឯង" ។

ទន្ទ្រាយថា "អើខាងចោទថាចងតឹងខ្លាំងខាងចម្លើយថាចងធូរ, ពាក្យទាំង២នេះសឹងពុំមានបន្ទាល់សាក្សីអាងអើបើដូច្នោះចៅក្រពើឯងលួនទៀងលើទូកនេះវិញ ឲ្យតាគាត់ចងម្តងទៀតយើងនឹងមើលឲ្យដឹងជាតឹង ឬធូរជាសាក្សីនឹងបានកាត់សេចក្តីនេះឲ្យជាយុត្តិធម៌ទៅបាន" ។

ឯក្រពើជាសត្វខ្លៅ ក៏ទាញទៀងទៅក្រាបលើទូកនេះឲ្យតានោះចងដូចមុន តានោះយកបំណងតាំងចងដូចមុនវិញ ទន្ទ្រាយសួរថា "ម្តេចចៅកុម្ភា, តាគាត់ចងតឹងយ៉ាងនេះឬ? ក្រពើក៏ឆ្លើយថា "ទេលោកកាលគាត់ចង់ខ្ញុំមុននោះ តឹងលើសនេះខ្លាំងណាស់បើចង់តែប៉ុណ្ណោះខ្ញុំនឹងទៅខឹងអ្វីនឹងគាត់" ។ ទន្ទ្រាយថា "អើ ចូរតាទីតខ្សែទ្វេទៀងទៀតឲ្យគេសុខចិត្ត" ។ តានោះក៏ទីតចំណងទៀងទៀត ។ ទន្ទ្រាយសួរថា "ម្តេចចៅកុម្ភាម្តងនេះតើជាតឹងដូចកាលជាន់មុននោះហើយឬ? ក្រពើថា "នៅពុំទាន់ស្មើចងមុននោះទេ" ។ ទន្ទ្រាយថា "តាឯងកាប់ឈើមកធ្វើជាកូនកំព្រាទីតម្តងទៀតទៅ" តានោះក៏ធ្វើតាមហើយតាំងត្រៃបែងទីតទាំងមុខទាំងក្រោយពេញកម្លាំង ឯក្រពើនោះត្រូវទៀត្រៃបែង

កូនកំព្រាខ្លាំងតឹងខ្លួនស្ទើរតែដកដង្ហើមចេញពុំបានទើបឆ្លើយ
ថា "សូមទានកាលជាន់មុននោះគាត់ចងតឹងយ៉ាងនេះឯង, លោក
អើយនរណាទៀយនឹងអត់បានសូមលោកជាសាកវ្ច័មើលចុះ ជា
អ្នកឯណាខ្មុសឯណាត្រូវ"។

ទន្ឋាយឃើញក្រពើខ្លួនពុំរួចហើយទើបបង្គាប់តានោះថា
"តាចាំអ្វីទៀតពូថៅធំក្នុងនេះនោះមិនយកមកពុះកឋ្ឋាលទាទៅ
ទុកឲ្យទេរស់ធ្វើអ្វីខ្មោចអាសត្វអកតញ្ញូពុំដឹងគុណគេដែលធ្វើលើ
ខ្លួន" តាចាស់នោះបានឱកាសដោយទន្ឋាយប្រាប់ដូច្នោះក៏ស្ទុះ
ទៅយកពូថៅធំមកសំពងកាប់កាត់ក្រពើនោះជាកំណាត់តូចធំ
ក្រពើដ៏លុះន្ងូវក្តីអន្តរាយជីវិតហោង។

សុភាទន្ឋាយបង្គាប់ថា "កង់កន្ទុយទានោះតាឯងឆ្អែនដាក់យក
ទៅស្តីសាឬចង់ញ៉ាំក៏ជា ឯពោះទៀនបត់ចន្ទាសទានោះញ៉ាំ
ភ្លាជាណាស់តាអើយ"។

ឯតានោះធ្វើតាមសុភាទន្ឋាយប្រាប់សព្វប្រការហើយយក
ចេកត្រសក់ជូនទន្ឋាយដោយក្តីខ្លួនផុតអន្តរាយនឹងក្រពើ ស្រេច
ហើយយកគោមកទឹមរទេះលាសុភាទន្ឋាយបរទៅកាន់ទីឋានន៍
អាត្មាហោង។

ក្រអើយក្រពើ គេមានគុណលើ មិនដឹងគុណគេ ចៅបានដល់ប៉ឹង
គឺតឹងបែបទេ ត្រឡប់ខាំគេ ឲ្យសូន្យជីវិត។ ធ្លាក់កលឧបាយ
សុភាទន្ឋាយ ឲ្យចង់ចៅភ្លិតនឹងទូកទេះ ស្រមេះអស់ទីទ្វេ
ចៅបង់ជីវិតដោយពូថៅតា។

តម្រាឃ្លាន គឺតបញ្ជោត លុះគេចោទ ឆោតប្រាប់គេ
កាលណោះ ព្រះពុទ្ធជាម្ចាស់យើង នៅក្នុងកាលសាងបញ្ញាបារមី
អន្ទោលជាតិ កើតជាសត្វពានរហៅថា មហាកបិន្ទ កបដោយ
កម្លាំងក្លាហានអាស្រ័យនៅព្រៃត្រើយស្ទឹងធំ១ ស្ទឹងនោះមាន
កោះ១ ឯក្រពើឮប្រពន្ធពោលដូច្នោះ ក៏លោមទៅថា "ទ័ហមេ
កុម្ភីមាសបង! នាងមានក្តីបំណងប៉ងសាច់ថ្លើមនៃពានរនោះ ជា
ភ្ជាក់ងារបងនឹងទៅរកមកឲ្យប្អូនបានក្នុងកាលថ្ងៃនេះ ព្រោះមា
នផ្លែទំ១ នៅខាងលើទឹយើងមានមហាពានរ១ តែងលោតឆ្លោះ
ឆ្លងពីត្រើយទៅកោះ ពីកោះទៅឯត្រើយទីញ្ញ ដូច្នេះបងនឹងទៅ
ចាំលាក់ខ្លួនពួនអែបនៅខាងដុំថ្មធំ ចាំគោះមហាពានរនោះត្រា
តែបាន", ថាហើយចៅកុម្ភាក៏ហែលលិលាត្រង់ទៅទីដុំថ្មធំ ដល់
ហើយតាំងទ្បើងក្រាបលើទីថ្ម ធ្វើអាការដូចថ្មដើម្បីពោធិសត្វ
សំគាល់ថាជាដុំថ្ម នឹងលោតទៅលើខ្លួននឹងដាយចាប់។

ឯមហាកបិន្ទរាជ លុះពេលល្ងាចត្រជាក់បរិភោគកបដោយផ្លែ
ឈើមើបឈើបរិបូណ៌ទឹកភ្លាលកោះនោះមានដីខ្សាច់និងដុំថ្ម១
ដុះនាកណ្តាលទីនោះជិតនឹងត្រើយ ពោធិសត្វតែលោតផ្លោះអំពី
ត្រើយទៅដល់កោះនោះ ដើម្បីស្វែងផលាផលរាល់ៗថ្ងៃ។

គ្រាកាលណោះមានសត្វក្រពើញីឈ្មោលជាប្តីប្រពន្ធអាស្រ័យ
នៅក្រោមស្ទឹងនោះឯង លុះនៅយូរមកមេក្រពើនោះធើមតី
មានគតិនឹងពងកើតក្តីទោហលាចំណង់ចង់ស៊ីថ្លើមពានរ ទើបនិយា
យនឹងក្រពើឈ្មោលថា "ខ្ញុំមានក្តីចង់ទទួលទានថ្លើមមហាពានរ
នោះជាខ្លាំងណាស់បើអ្នកមិនគិតរកឲ្យខ្ញុំបរិភោគក្នុងសម័យ
នេះខ្ញុំនឹងស្លាប់ចោលអ្នកឯងជាប្តីសម្លាញ់ហើយ"។

ផលាផលឆ្អែតហើយនឹងទិលទៅខាងត្រើយនាយទីញុះលុះលោ
តចុះចាកកោះផ្លោះមកដល់ទីឆ្នេរស្ទឹងហើយនឹងលោតទៅជាន់
ដុំថ្មកណ្តាលនោះ បែរទៅឃើញក្បាលក្រាបលើថ្ម ក៏កើតក្តី
សង្វល់គិតថាថ្មនេះសព្វកាលទៀងមក តែងទាបត្រឹមខ្នងទឹក
នេះទេ ថ្ងៃនេះហេតុអ្វីក៏ថ្មនេះខ្ពស់ដូច្នេះទំនងជាមានសត្វកំណាច
មកដេកក្រាបលើថ្មនេះ ដើម្បីយាយីជីវិតអាត្មាប្រាកដ ពោធិ
សត្វគិតដូច្នោះហើយ ក៏ពោលពាក្យហៅទៅថា "ហែដុំថ្មដ៏...

ប្រសើរអើយ! អើខ្លួនចៅឯងនេះសព្វកាលទៀងមកពុំដែលលូតខ្ពស់ហួសអំពីខ្នងទឹកនេះទេថ្ងៃនេះ ហេតុអ្វីក៏ថ្មឯងលូតខ្ពស់លើសកាលមុនៗហះ? ពោធិសត្វពោលហៅថ្មយ៉ាងនេះ មិនតែម្តងគឺហៅអស់វារៈ៣ដង។

ឯក្រពើក្រាបលើថ្ម ឮពានរហៅថ្មជាគំរប់៣ ដងក៏គិតថាថ្មនេះកាលពីដើមទំនងជាចេះនិយាយទើបបានពានរនេះហៅប្រស្រ័យ ឥឡូវឯងមកដេកក្រាបលើខ្នងវា បានជាវានិយាយតទៅនឹងស្វាទីញុះពុំរួច បើដូច្នោះមានតែអញ្ជើឯងក្តែងនិយាយដួសថ្មនេះទើបបានស្វានេះវាលោតមក ព្រោះថ្មនេះនឹងស្វានោះគេធ្លាប់ចរចាប្រស្រ័យនឹងគ្នា គិតហើយចៅក្អែម្នាក់ឆ្លើយតបទៅថា "ហែមហាកបិន្ទរាជ អ្នកឯងសង្ស័យនឹងយើងថា លូតខ្ពស់ហួសអំពីមុននោះឬ? យើងតាំងនៅដដែល ដូចកាលមុននោះទេអញ្ជើញលោតមកជាន់យើងដូចកាលមុនៗនោះចុះ"។

ឯបរពោធិសត្វ បានឮក្រពើពោលតបមកដូច្នោះក៏ថា "ភោនរណាមកពោលពាក្យតនឹងយើងនេះថ្មយើងធ្លាប់ជាន់នេះ មិនចេះនិយាយជាភាសាលោកទេ នេះគឺរូបនរណាពោលប្រាប់មកយើងនេះ"។

ឯក្រពើនោះលុះឮដូច្នោះក៏ទាល់បញ្ឆានឹងគេចខ្លួនពុំរួចទើបឆ្លើយប្រាប់តាមក្តីពិតថា "យើងនេះគឺជួមហាកុម្ភានៅនាទីស្ទឹងនេះណ៎ាពានរ"។

"ឱចៅមហាកុម្ភាទេហ៎! អើហេតុអ្វីក៏ចៅមកដេកក្រាបលើថ្មនេះ?"។ "នែចៅពានរយើងនេះមានសេចក្តីប្រាថ្នាចង់បានសាច់ថ្លើមបេះដូងនែចៅឯងនឹងនាំទៅឲ្យភរិយាយើងបរិភោគ"។

"ឱ! បើចៅប្រាថ្នាជីវិតយើងដូច្នោះចូរចៅហាមាត់ធ្មេចភ្នែកទៀង យើងនឹងលោតទៅត្រង់ឥទ្ធរនេះ។ ឯក្រពើនោះក៏តាំងហាមាត់ទៀងចង្អ្គាងធំធ្មេចភ្នែកទាំង២ ជិតប្រុងចាំត្របាក់ពានរ។ ឯពោធិសត្វមានឱកាសហើយក៏លោតផ្លោះស្ទុះទៅអំពីទីទាបត្រង់ទៅជាន់លើកឆ្ការលចៅកុម្ភាហើយផ្លោះទៅដល់ត្រើយនាយដោយកម្លាំងខ្លាំងលឿន ដូចខ្យល់មួយរំពេច ពោធិសត្វក៏ទៅដល់ទីលំនៅនៃអាត្មា។

ឯមហាកុម្ភាដឹងថាពានរលោតផុតខ្លួនៗចាប់ពុំទាន់ដូច្នោះ ក៏តឹតក្តីទោមនស្សតូចចិត្ត ដោយចាញ់កលមហាបិន្ទវាជ តឹអាត្មាឆោតខ្លៅពិតៗ ហើយក៏ចុះពីខ្នងសិលាម្ខ្មុម្ខា ហែលទៅកាន់ទីទួងឆ្ការលកោះជាទីលំនៅអាត្មាវិញហោង។

ទៀងនិទាននេះ មានសេចក្តីពិស្តារនៅក្នុងគម្ពីរចរិយាបិដកឯណោះមើលចុះ។

(ចប់រឿងឆោតដោយក្តីឃ្លានអាហារ)

តម្រាឆោតដោយស្រទឹងយសទ្បើងបញ្ចេរ

(ពាក្យអានជាបទ) កាកតិតែង តំណាល់តែណែង ដំណើរបក្សា ក្អែកគោកមួយនៅ លើចុងរុក្ខា សែនសុខស្តាពរពិតឥតមោះ។ ថ្ងៃ១បក្ស ចេញស្វែងចំណី តាមភូមិកៀនកោះ ឃើញអ្នកនិគម ហាលនំទឹកដោះ ក្អែកអរនហើយផ្លោះ ចុះចោះចឹកបាន។ កាងស្តាបហើរស្តៅ តម្រង់ត្រង់ទៅ បែរមើលទីឋាន ដានដែលយាត្រា។ កាលនោះមានសត្វ សំពោច១ធាត់ស្វែងរកភោក្តា មកដល់យល់ក្អែក ទំមែកនុក្ខាមាត់ពាំនំប្រាកដជាចំណី។

សំពោចគិតថា អញនឹងចរចា បញ្ឆោរបក្ស ឲ្យទាហាមាត់ភ្លាត់ធ្លាក់ចំណី ជ្រុះមកដល់ដី បានអញទិញ្ញាណ។ គិតហើយទើបពោល ជាពាក្យបញ្ឆោរ ទៅកាន់ក្អែកថា ក្អែកអើយអ្នកក្អែកទូបឯកសោកាចំពុះដូចជា ខ្ញុំនកែវមរកដ។ នាមស្តាបស្រស់ស្រិល រលង់ដូចនិល រលើបម៉ត់ចត់ ចង្កេះសមទ្រង់ ជង្គង់សមបទ ទង់មុខសមមាត់ សមមានលក្ខណា។

នូបអ្នកឧត្តម បើតាមក្បួនខ្ញុំ ទំនាយទាយថា នឹង បានសម្រេច
ជាស្តេចបកក្បា តែសិព្ធសនា ពុំទាន់ប្រត្យ័ត្ត។ បើសិនអ្នកស្រែ
ខ្ញុំឮសម្រែក សូនសមចំសិក្ខ ខ្ញុំហ៊ានទំនាយ ទាយថាអ្នកជាក់ បាន
ជាចមចក្រ កំពូលបកក្បា។

ក្អែកទៀងអួត ឮគេសង្ឃត សនសើនអញ្ជើ ចង់ឲ្យគេស្តាប់
សូនសិព្ធសនា ទើបឈនទៀងហា មាត់ស្រែកចេញខ្ញើ។ ឯនំពាំ
នោះ ធ្លាក់ពីចំពុះ ជ្រុះមកដល់ដី សំពោចស្រុះស្រួល ទទួលចំណី
ហើយបែនស្រដី ចំអកបកក្បា។ ក្អែកអើយចៅក្អែក អ្នកឯង
បែងចែក ចំណីនេះណា យើងពេញចិត្តគាប់ចិត្ត ដ្បិតអ្នកយល់
ថា យើងជាហោរា ទទួលខាន់ខៅ។ ជាហើយចៅក្អែក ប្រព្រឹត្ត
នេះឯក ឥតមានហ្មងសៅ អ្នកឯងទៅរក មកទៀតណ៎ាចៅ ពី
ថ្ងៃនេះទៅ យើងបានពឹងផង។ ថាហើយសំពោច បែនប្រាណ
ស្ទុះផ្លូច ចូលព្រៃដូចប័ង កាកោបង់នំ ក្រំចិត្តកន្លង ពុំដឹងទំនង
ខ្មោចលងភក្បា។

នីទានទៀងនេះ អញ្ជើញប្រាប់ចេះ ត្រែះមើលកិរិយា ក្អែក
ចង់ចំណី ព្រោះក្តីប្រាថ្នា ក្នុងបសំសា បាយ័សង្ឃត។

នរូអ្នកណា មានចិត្តប្រាថ្នា ចង់ឲ្យគេអួត នឹងដូចក្អែកខ្មៅ

ត្រូវគេសង្ឃត ឆោតទៀងអំនួត បង់នំឯងអើយ។

(ចប់តម្រោធោតព្រោះសរសើរ)

តម្រោធោតព្រោះមាន

(ពាក្យបទព្រហ្មគីត) តម្រោកម្រើកចិត្ត អាងឥទ្ធិរិទ្ធិ ឥតវិញ្ញាណ
ថាគ្រានោះមែនមាន សត្វចចកមួយអប្រិយ។ នៅក្នុងគោហា
ស្ងាត់ អស្រ័យសត្វជាចំណី ដោយសារសត្វរាជសីហ៍ ជាមិត្រភ័ក្តិ
ស្មោះស្មាគម។ ថ្ងៃ១ចចកចរ ទៀងសិង្ឃរចូល យល់ថ្មដា១ធំ ភ្លឺ
ដូចថានកញ្ចក់ឆ្នុះ។ ចចកយល់ថា នៃអាត្មានៅក្នុងនោះ ដឹងជា
ស្រមោលច្នោះ កើតកួចចិត្តគិតទ្រុស្តមិត្រ។
គិតថាទៅមុសាប្រាប់សីហា ក្រកបប្បទិ ថាមានបច្ចាមិត្ត
ចង់លងប្បទិដំនាញ្ជ័យ។

មិត្រអញ្ជើកាន់មាន អាងតបះកំហែងហល់ តែថាបញ្ញាទាល់
យល់ស្រមោលគង់បោលជាក់។ មែនបើមិត្រប្រហារ ត្រូវថ្មដា
នោះជ្រៀងជាក់ គល់កមិត្រគង់បាក់ សូន្យជីវិតពិតពុំខាន។

បើរាជសីហ៍ស្លាប់ សាច់ជាភក្ខអញ្ជើឯងបាន អាស្រ័យទទួល
ទាន ឃើញជាមានរស។ ជាហើយ ពុំលង់ទ្បើយ
ទើបយាត្រា ទៅប្រាប់រាជសីហា ដល់ហើយថាហែមហាមិត្រ។

ឥឡូវនៃមានរាជសីហ៍ មួយនៅទីល្អាងទីចិត្រ អួតថាខ្លួនប្រសិទ្ធ
ចង់លងឬទ្ធិនឹងមិត្រឯង។

រាជសីហ៍ស្តាប់ចចក និយាយឡកដោយកលលេង ស្មានពិតដូច
ពាក្យថ្លែង កើតជឿចិត្តឥតសង្ស័យ។ ទើបតបថាអើចៅ មក
យើងទៅជំនាញ់ជ័យ ខ្លាចអ្វីអាសត្វព្រៃ នៅឯណាំចចក។

ចចកនាំរាជសីហ៍ ទៀងតីរីកាត់ឈូងចក ដរាបទៅដល់ច្រក
ល្អាងសិលាថ្មដាឆ្នុះ។ ចចកក្លែងធ្វើខ្លាច មកក្រោយរាជសីហ៍ស្មោះ
ខ្ញុំបថាហ្ន៎អើនោះ មិត្តមើលចុះនោះវាហើយ។ វាគ្មានព្រមមិត្ត
ទេ ឈរចំអែនៅកន្លែយ បើមិត្តធ្វើម្តេចហើយ វាក៏ធ្វើតបវិញ
ស្តែង។ រាជសីហ៍ជឿស្ទុះចូល ឃល់ស្រមោលអាត្មាឯង ស្មានសត្វ
ដទៃផ្សេង ទើបសម្តែងឫទ្ធិសីហ។ ស្ទុះក្រាបចាក់ក្រាញ់ក្រោយ
កន្ទុយកោយកន្ទុះរាសំញ្ញេញ្ញាក់ភក្ត្រា ធ្វើកំរិយាចូលជាញ្ញ
ជ័យ។ រូបភាពស្រមោលនោះ ខ្លួនធ្វើដូច្នោះវាច្នោះនែ រាជសីហ៍
ទោសោកក្រៃ ស្ទុះទះទល់ជល់ថ្មដា។ លុះត្រូវសិលាឡាក់ កក៏បាក់
ដល់ពីការ រាជសីហ៍សូន្យសង្ឃាន នៅនាកាលនោះឯងនែ។

អនិច្ចាសត្វសីហោ ភ្លើងទោសោដុតឲ្យក្រ័យ មោហោបញ្ញា
ខ័យ ជំនាញ់ជ័យនឹងរូបឯង។ លុះនៅវិនាសប្រាណ នេះព្រោះ

គ្មានបញ្ញាឈ្លេង យកតែមានះឯង មកសម្តែងតាំងជាមុខ។ មានះ
នេះខូចខ្លួន ចុះក្នុងកន្លែនលោកតាំងទុក មានះនាំបុកនុក នាំមនោ
ឲ្យម្ញេអើយ។

(ចប់តម្រោធោតឆាងអាងមានះ តែត្រឹមនេះហោង)

តម្រោធោតព្រោះឃ្លានមាន

មានចៅព្រានព្រៃម្នាក់តែងដើរបរបាញ់សត្វម្រឹគបក្សីយក
មកចិញ្ចឹមជីវិតនៅជាប្រក្រតី ថ្ងៃ១ចៅព្រានព្រៃទៅស្វែង
បរបាញ់ក្នុងព្រៃលុះពេលល្ងាចក៏ត្រឡប់វិលមកផ្ទះ ដើរមក
ដល់ព្រៃ១មានដើមឈើធំ១ដើម ដុះនៅខាងផ្លូវមានមេសេក១
ទៅធ្វើសំបុកភ្ញាស់កូន នៅលើចុងឈើនោះឯង។

ចៅព្រានព្រៃដើរមកជិតនោះហើយពោលពាក្យថា ថ្ងៃនេះ
ពេលក៏ជួនល្ងាចណាស់អញ្ចឹងឯទៀងយកកូនសេកនៅសំបុកនេះ
ពុំទាន់ បើដូច្នោះ ចាំព្រឹកស្អែកចុះនឹងមកយកវាទៅស្លសុី ថាហើ
យចៅព្រានព្រៃក៏ដើរហួសទៅផ្ទះ។

ឯមេសេកនៅលើសំបុក លុះបានឮពាក្យព្រានព្រៃគុំនឹងយា
យីដូច្នោះ ក៏កើតក្តីភ័យសោកស្តាយបុត្រ នឹងជីវិតអាត្មាថា
ឮម្តិអញ្ចឹអើយ! កើតមកជាសេកនេះ ជាសត្វឥតពិសឥតអាវុធ

នឹងតនឹងមនុស្សនោះសោះ ឥឡូវទៀងថាព្រឹកស្អែកនេះទានឹងមកយកកូនអញ្ជើទៅអាស្រ័យ ឱ! បើកូនអញ្ជើដល់នូវទៀសេចក្តីវិនាសហើយ តើជីវិតអញ្ជើឯណាក៏នឹងតាំងនៅបានគង់អញ្ជើស្លាប់តាមកូនអញ្ជើមិនលែងទេឱ្យ, ឱកូនអញ្ជើអើយ! តូចៗពេកពុំទាន់ដុះក្រាសដុះស្លាបឲ្យមាំមួននឹងបាននាំបង្ហើរចេញឲ្យផុតអំពីសត្រូវនេះ, មួយទៀតអញ្ជើនឹងតតេរកសត្វណា អាចនឹងជួយបានអេះ! ។

ឱ! បើតតទៅឃើញខ្មុបាយ១ ល្មមកែខ្លួនបានតអញ្ជើមានសត្វពស់ទែក១ នៅឯដំបូកខាងនោះ ពស់នោះជាសម្លាញ់នឹងអញ្ជើមកយូនហើយ ចាំអញ្ជើទៅនិយាយ ឲ្យសម្លាញ់ជួយដោះទុក្ខនេះទើបបាន កាលដែលសេកនោះ តតដូច្នោះក៏ហើរទៅកាន់សំណាក់ពស់ ដល់ហើយក៏និយាយប្រាប់ពស់ តាមទើងចៅព្រានព្រៃវានឹងមកចាប់កូនខ្លួន ក្នុងទៀលាថ្ងៃព្រឹកនេះឯង ។

ឯពស់ទែកឮដូច្នោះក៏អាណិតសេកជាសម្លាញ់ទើបទទួលជួយដោះទុក្ខសេក ទើបផ្តាំសេកថា បើព្រានោះវាទើងនឹងយកកូនសេកឯងកាលណា ឲ្យសេកឯងនិយាយអង្វរសូតវាថា ខែឯងតែអ្នកមេត្តាកុំយកកូនខ្ញុំចុះ ខ្ញុំនឹងប្រាប់ទីកំណប់មានប្រាក់កែវកងនៅទីដំបូកនោះឲ្យអ្នក ក៏ឯងជាតិមនុស្សនោះតែឮត្រង់កំណប់

មាសប្រាក់ហើយ គង់ចង់បានលើសកូនសេក ១២ នោះជា ១០០ គុណគង់ឲ្យសម្លាញ់ឯងនាំផ្លូវវាមកដំបូកនេះ សម្លាញ់ឯងចូរប្រាប់វាថាទីត្រង់នេះហើយ វានឹងលូកដៃមកក្នុងរន្ធនេះមិនខាន បើវាលូកដៃមកកាលណាហើយ ខ្ញុំឯងនឹងចឹកវាឲ្យលុះដល់មរណកាលនាទីនេះឯង ឯសម្លាញ់ឯងក៏នឹងរួចអំពីអន្តរាយ ។

មេសេកនោះបានស្តាបខ្មុបាយពស់ប្រាប់ដូច្នោះហើយ ក៏ត្រអរនៃក្រពេក ទើបលាពស់ហើរទីលឆ្ពោះមកទ្រនំទីញ ចូលក្រាបគ្របគ្រងកូននៅអស់មួយរាត្រីកាល លុះអរុណទ្រើងរះស្រឡះ មេឃាចៅព្រានព្រៃក៏ម្ចុំម្នាទៀបអាត្មា ទៅកាន់ដើមឈើធំ ដល់ហើយក៏លាត់សំពត់វិណ្ហែតាតខ្ជាប់ទៅឯដើមឈើ ដើម្បីយកកូនសេក ។

ឯមេសេក ឃើញចៅព្រានទៅជិតដល់ប្រតាបឈើកាលណាក៏សុះហើរមកទំមែក១ ហើយនិយាយទៅថា បពិត្រអ្នកជាមនុស្សអ្នកឯងខំព្យាយាមទៅឯឈើនេះ ដើម្បីសាច់កូនសេកនឹងសាច់ខ្ញុំជាមេនេះ សេចក្តីប្រាថ្នាអ្នកនឹងសម្រេចហើយ តែសាច់កូនសេកនឹងសាច់ខ្ញុំនេះ អ្នកបរិភោគទៅក៏បានឆ្អែតតែក្នុងថ្ងៃនេះឯង ដល់ថ្ងៃស្អែកខានស្អែក អ្នកនឹងឃ្លានទីញ ហេតុ

នោះចូរអ្នកកុំប្រាថ្នាសាច់សេចស៊ី១ ពេលនេះទៀយចូរអ្នកចុះ
ទៅយកកំណប់ឯទីជើងដំបូកឯណោះវិញ្ញ មានប្រយោជន៍លើស
លែងសាច់សេកនេះជា១០០គុណ។ បើអ្នកចង់បានខ្ញុំឯងហើរនាំ
អ្នកទៅកាន់ទីកំណប់នោះ។

ឯចៅព្រានព្រៃបានឮសេកប្រាប់ទីកំណប់ដូច្នោះក៏ត្រេអរ
ក្រៃពេកណាស់ទើបថាអើសេកបើឯងប្រាប់ទីកំណប់ អញ្ញបាន
មាសប្រាក់ដូចឯងថានេះហើយ អញ្ញលែងយកកូនសេកឯង មក
យើងទៅវិញ្ញទៅនេះ ថាហើយក៏ចុះចាកឈើលុះដល់ដី មេសេក
បក្រឹក៏ហើរនាំផ្លូវទៅត្រង់ដំបូកអាសិរពិសពស់នៃកដល់ហើយ
ក៏ស្រែកប្រាប់អំពីលើថា អ្នកព្រានព្រៃនោះហើយទីនណ្តៅកំ
ណប់មាសប្រាក់ តាមចិត្តអ្នកប្រាថ្នាកាយយកចុះ។

ឯចៅព្រានចង់មានខ្លាំងក៏តាំងលូកដៃចុះទៅក្នុងរន្ធពស់ដោ
យឥតពិចារណាឯពស់នៃកនោះ ក៏ចឹកដៃព្រានព្រៃមួយរំពេច
ពិសពស់នោះក៏ផ្សព្វផ្សាយកាយចៅព្រានព្រៃ ដល់ក្តីមរណកាល
នៅជើងដំបូកនោះឯង។

ឯមេសេកឃើញ្ញចៅព្រានព្រៃដល់ក្តីមរណៈ ក៏អស់ក្តីសត្រូវ
ខ្លួនពីថ្ងៃនេះឯង ហើយក៏ហើរនាំទៅទ្រុំ ទំគ្រប់គ្រងព្យាបាល

កូនដរាបចម្រើនធំនាំទៅរកស៊ីតាមនិស្ស័យហោង។

ចប់ តម្រោតឃ្លានមានអន្តរធានព្រាណ។

ចប់ភាគ៣ តែប៉ុណ្ណោះ។